# សេចក្តីសង្ខេប
# (Executive Summary)

## ១. សេចក្តីផ្តើម

ក្នុងបរិយាកាសនៃស្ថានភាពបច្ចុប្បន្ននេះ មុខសញ្ញាវិនិយោគគ្រប់ប្រភេទសុទ្ធតែមានសារៈសំខាន់សម្រាប់កម្ពុជាទាំងអស់ ទាំងការវិនិយោគផលិតទំនិញនាំចេញ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគលើវិស័យឧស្សាហកម្ម កសិកម្ម កសិ-ឧស្សាហកម្ម ការស្វែងរកប្រភពទាក់ទាញទេសចរណ៍ សេវាកម្ម និងការផលិតថាមពលអគ្គិសនីដោយប្រើចរន្តទឹក គឺវារីអគ្គិសនី ដែលជាសក្តានុពលដ៏សំខាន់នៃការរីកចំរើន នៃសេដ្ឋកិច្ចរបស់កម្ពុជា។

ផ្អែកតាមគោលនយោបាយខាងលើគម្រោងវារីអគ្គិសនីនៅប្រទេសកម្ពុជា ត្រូវបានធ្វើការវិនិយោគជាច្រើនកន្លែង ដោយឡែក គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ខេត្តពោធិ៍សាត់ ត្រូវបានចាប់អារម្មណ៍ពីក្រសួងរ៉ែ និងថាមពលផងដែរ។ គម្រោងវារីអគ្គិសនីនេះ បានធ្វើការសិក្សា ៣ ជំហ៊ានសំខាន់ៗគឺ ១) ការសិក្សាបុរេសមិទ្ធលទ្ធភាព ដោយក្រុមហ៊ុន HEC ២) ការសិក្សាសមិទ្ធលទ្ធភាព ដោយក្រុមហ៊ុន HEC ការសិក្សាទាំងពីរនេះ វារីអគ្គិសនីនេះមានលទ្ធភាពបំពាក់ទួរប៊ីនកម្លាំង ៤០MW ហើយដំណើរការផលិតអគ្គិសនី១ឆ្នាំពេញ។ ៣)ការធ្វើបច្ចុប្បន្នភាពសមិទ្ធលទ្ធភាព ដោយក្រុមហ៊ុន SINOHYDRO វារីអគ្គិសនីនេះ មានលទ្ធភាពបំពាក់ទួរប៊ីនកម្លាំង ៨០ MW ហើយដំណើរការផលិតអគ្គិសនី ៦ខែពេញនៅរដូវប្រាំងវិញ។

គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ នេះវិនិយោគដោយ ក្រុមហ៊ុន KTC Cable Co., Ltd (KTC) ដោយជ្រើសឱ្យក្រុមហ៊ុន Hyundia Engineering Co., Ltd (HEC) ជាទីប្រឹក្សាបច្ចេកទេស។ ឯ.ឧ អ៊ិត ប្រាំង រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល បានចុះហត្ថលេខា នៅខែមករា ឆ្នាំ២០១០ បានឱ្យក្រុមហ៊ុន KTC Cable Co., Ltd (KTC) សិក្សាបុរេសមិទ្ធលទ្ធភាពនៃគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះឡើង។ ហើយនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១ ឯ.ឧ អ៊ិត ប្រាំងរដ្ឋលេខាធិការក៏បានអនុញ្ញាតិ ឱ្យក្រុមហ៊ុន KTC ធ្វើការសិក្សាសមិទ្ធលទ្ធភាពបន្តទៀតលើគម្រោងនេះ ចាប់ពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២។ ក៏ប៉ុន្តែក្នុងរយៈពេលនេះ ក្រុមហ៊ុននេះមិនអាចបញ្ចប់នូវការសិក្សានេះបានទេ ដោយសារក្នុងតំបន់គម្រោងគ្មានផ្លូវចេញចូល និងកត្តាផ្សេងទៀត ដូចនេះនាថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១ ក្រុមហ៊ុន KTC បានសរសេរលិខិតស្នើសុំពន្យារពេលសម្រាប់ការសិក្សានេះ ទៅក្រសួង។ ឯ.ឧ ស៊ុយ សែម រដ្ឋមន្ត្រីនៃក្រសួងរ៉ែ និងថាមពល បានចុះហត្ថលេខាអនុញ្ញតឱ្យពន្យារពេល នៃការសិក្សាសមិទ្ធលទ្ធភាពនេះ ដល់ខែធ្នូ ឆ្នាំ២០១២ វិញ។

យោងតាមការធ្វើបច្ចុប្បន្នភាពសមិទ្ធិលទ្ធភាពគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ មួយថ្មីទៀត ដែលសិក្សាដោយ Power China / SINOHYDRO របស់ប្រទេសចិន ដែលទើបបានបញ្ចប់ នៅខែវិច្ឆិកា ឆ្នាំ២០១៧ គម្រោងនេះ ដំណើរការនៅរដូវប្រាំង ដោយយោងតាមតម្រូវការរបស់ EDC រយៈពេល៦ខែពេញ ដែលអាចផលិតអគ្គិសនីបាន ៣៦៧,១២ លាន kWh/ឆ្នាំ និងដំឡើងទួរប៊ីន ២ ហើយមានកម្លាំងសរុប ៨០MW វិញ។ គម្រោងនេះ គ្រោង នឹងវិនិយោគ ជាប្រវត្តិសាស្ត្រ រួមគ្នារវាងក្រុមហ៊ុន KTC, ក្រុមហ៊ុន K WATER, ក្រុមហ៊ុន TURBEN Investment របស់ប្រទេសកូរ៉េ (ខាងត្បូង) និងក្រុមហ៊ុន SINOHYDRO របស់ប្រទេសចិន (KTC ជាក្រុមហ៊ុន តំណាងឱ្យម្ចាស់គម្រោងនៃក្រុមហ៊ុនទាំង៤នេះ ហើយក្នុងការពិពណ៌នាក្នុងរបាយការណ៍នេះ គឺយកឈ្មោះKTC មកបរិយាយប៉ុណ្ណោះ ព្រោះ KTC ជាអ្នកទទួលបានការអនុញ្ញាតពីក្រសួងរ៉ែ និងថាមពលឱ្យសិក្សាគម្រោងនេះ)។

## ២. វិធីសាស្រ្តនៃការសិក្សា

ចំណុចសំខាន់ៗនៃវិធីសាស្រ្តក្នុងការសិក្សាលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ (ESIA) របស់គម្រោងវិនិយោគលើវិស័យវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ស្ថិតនៅស្រុកវាលវែង ខេត្តពោធិ៍សាត់ របស់ក្រុមហ៊ុន KTC នេះមានយន្តការនៃវិធីសាស្រ្តសិក្សាធនធានបរិស្ថានទាំងបីគឺ បរិស្ថានរូបសាស្រ្ត បរិស្ថានជីវសាស្រ្ត និងបរិស្ថាន សេដ្ឋកិច្ចសង្គមបានធ្វើឡើង រួមមានដូចតទៅ:

Draft

- ប្រមូលទិន្នន័យ និងព័ត៌មានដែលទាក់ទងជាមួយស្ថាប័នពាក់ព័ន្ធទាំងអស់នៅភ្នំពេញដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងបរិស្ថាន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងរ៉ែ និងថាមពល, ក្រសួងផែនការ, NGOs, សាម៉ីក្រុមហ៊ុន និងស្ថាប័នទាក់ទងមួយចំនួនទៀត។ ការចុះប្រមូលទិន្នន័យដល់ទីតាំងភូមិសាស្ត្ររបស់គម្រោង និងមានការប្រឹក្សាពិគ្រោះយោបល់ពីសាធារណជន, មេភូមិ, មេឃុំ, អភិបាលស្រុក និងស្ថាប័នពាក់ព័ន្ធដូចជា មន្ទីររ៉ែ និងថាមពលខេត្ត, មន្ទីរកសិកម្មខេត្ត, មន្ទីរបរិស្ថានខេត្ត, មន្ទីរធនធានទឹកខេត្ត, មន្ទីរដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត, ខណ្ឌរដ្ឋបាលព្រៃឈើ និង អង្គការមិនមែន រដ្ឋាភិបាល (NGOs) មួយចំនួន។
- ការចុះអង្កេតសិក្សាពីបរិស្ថានធម្មជាតិដោយផ្ទាល់លើទីតាំងគម្រោងដូចជា ការសិក្សាប្រព័ន្ធជលសាស្ត្រ, ភូគព្ភសាស្ត្រ និងដី, ព្រៃឈើ, សត្វព្រៃ, មច្ឆជាតិ ។ល។ ដោយមានការបង្ហាញពីអ្នកភូមិផ្ទាល់ (លទ្ធផលការរាប់ព្រៃមានចែងក្នុងតារាង៥-២៦, ៥-៣៤, ៥-៣៥, ៥-៣៦។
- ការចុះអង្កេតសិក្សារកដីដែលប្រើប្រាស់ (ដីប៉ះពាល់) របស់ប្រជាពលរដ្ឋក្នុងតំបន់ទីតាំងគម្រោង (សូមពិនិត្យមើលផែនទី លេខ៣ និងលេខ៤)។
- ការចុះជួបផ្ទាល់ជាមួយប្រជាពលរដ្ឋ ដែលមានដីប៉ះពាល់ក្នុងតំបន់អភិវឌ្ឍន៍គម្រោង ដើម្បីសម្ភាស និងសិក្សាស្វែងយល់ពីជីវភាពរស់នៅរបស់ពួកគេមុនពេលអភិវឌ្ឍន៍គម្រោង។
- ការយកគំរូសាក និងធ្វើការវិភាគលើគុណភាពទឹកផ្ទាល់នៅប្រភពធនធានទឹកលើដី និងក្រោមដី (សូមពិនិត្យមើលតារាងតេស្តទឹកនៅទីកន្លែងផ្ទាល់របស់គម្រោងក្នុងឧបសម្ព័ន្ធ២) ដើម្បីរកកម្រិតគុណភាពប្រភពទឹកដើមមុនការអភិវឌ្ឍគម្រោង។
- ធ្វើការវិភាគទិន្នន័យទាំងអស់ ដែលប្រមូលបាន និងរៀបរាប់អំពីស្ថានភាពបរិស្ថានធម្មជាតិ និងសង្គម ដែលមានស្រាប់រួចធ្វើការប៉ាន់ប្រមាណពីស្ថានភាពបរិស្ថានទាំងនោះ ដែលអាចកើតមានឡើងនៅក្នុងកំឡុងពេលរចនាប្លង់សាងសង់ ប្រតិបត្តិ និងថែទាំ និងបញ្ចប់គម្រោង។
- បើកសិក្ខាសាលា ដើម្បីធ្វើការពិភាក្សា កែតំរូវ និងបំពេញបន្ថែមចំណុចខ្វះខាត នៅខេត្តដែលគម្រោងស្ថិតនៅដើម្បីឱ្យឱកាសតំណាងប្រជាពលរដ្ឋមូលដ្ឋាន អង្គភាព និងមន្ទីរពាក់ព័ន្ធជុំវិញខេត្តបានចូលរួម។
- ពិនិត្យ និងសំរួលឡើងវិញនូវផែនការមេរបស់គម្រោង។
- កំណត់ទំហំឥទ្ធិពលហេតុប៉ះពាល់អវិជ្ជមាន និងវិជ្ជមានដែលបណ្តាលមកពីសកម្មភាពរបស់គម្រោង។ រិះរកវិធានការណ៍កាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថានអវិជ្ជមានឱ្យដល់កម្រិតអប្បបរមា ហើយធ្វើឱ្យប្រសើរឡើងនូវហេតុប៉ះពាល់បរិស្ថានវិជ្ជមានឱ្យដល់កម្រិតអតិបរមាដោយដកស្រង់ពីការប្រឹក្សាជាសាធារណៈ និងសំណូមពរផ្សេងៗពីប្រជាពលរដ្ឋ និងស្ថាប័ន ដែលពាក់ព័ន្ធក្នុងតំបន់គម្រោង។
- រៀបចំផែនការគ្រប់គ្រងបរិស្ថាន Environmental Management Plan (EMP) ដោយមានដាក់កម្មវិធីត្រួតពិនិត្យ (Monitoring Program) នៅក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិ ថែទាំគម្រោងទៀតផង។ ចំពោះការសិក្សាទៅតាមធនធានបរិស្ថានរូបសាស្ត្រ. ជីវសាស្ត្រ និងធនធានបរិស្ថានសេដ្ឋកិច្ចសង្គម។

## ៣. ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ

ដើម្បីធ្វើឱ្យគម្រោងមានការអភិវឌ្ឍបានល្អ ក្របខណ្ឌច្បាប់ចំនួន ១៦ និងអនុក្រឹត្យចំនួន ៧ ដែលពាក់ព័ន្ធដូចខាងក្រោមត្រូវសិក្សា និងអនុវត្តន៍។

**ក្របខណ្ឌច្បាប់មានដូចជា:**

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២. ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ ២០០៨

៣. ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ ១៩៩៦
៤. ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ឆ្នាំ ២០១១
៥. ច្បាប់ស្តីអស្សាមិករណ៍ ឆ្នាំ ២០១០
៦. ច្បាប់ស្តីពីទេសចរណ៍ ឆ្នាំ ២០០៩
៧. ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧
៨. ច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦
៩. ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ឆ្នាំ ២០០៥
១០. ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៣
១១. ច្បាប់ស្តីពីវិនិយោគ ឆ្នាំ១៩៩៤
១២. ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ ២០០២
១៣. ច្បាប់ភូមិបាល ឆ្នាំ ២០០១
១៤. ច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០០
១៥. ច្បាប់ស្តីពីការងារ ឆ្នាំ ១៩៩៧
១៦. ច្បាប់ស្តីពីពីវិសោធនកម្មមាត្រា ១៣៩ និង ១៤៤ នៃច្បាប់ស្តីពីការងារ ឆ្នាំ ២០០៧
១៧. ច្បាប់ស្តីពីការរៀបចំទឹកដីនគររូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤
១៨. ច្បាប់ស្តីពីសារពើពន្ធ ឆ្នាំ ១៩៩៧
១៩. ច្បាប់ស្តីពីរបបសន្តិសុខសង្គម ឆ្នាំ ២០០២
២០. ច្បាប់ស្តីពីផ្លូវថ្នល់
២១. ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ឆ្នាំ ២០១៤
២២. ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ឆ្នាំ ១៩៩៦
២៣. ច្បាប់ស្តីពីសម្បទាន

**អនុក្រឹត្យមានដូចខាងក្រោម:**

១. អនុក្រឹត្យ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ ១៩៩៩
២. អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច ឆ្នាំ ២០០៣
៣. អនុក្រឹត្យស្តីពីការបង្កើតឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ឆ្នាំ ២០១៦
៤. អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងឆ្នាំ ២០០០
៥. អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក ឆ្នាំ ១៩៩៩
៦. អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់រឹង ឆ្នាំ ១៩៩៩
៧. អនុក្រឹត្យ ស្តីពីការគ្រប់គ្រងអាងទន្លេ ឆ្នាំ ២០១៥
៨. អនុក្រឹត្យស្តីអំពី ការកំណត់ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
៩. អនុក្រឹត្យស្តីអំពី ការបង្កើតមូលនិធិបរិស្ថាន និងសង្គម ឆ្នាំ ២០១៦

**គោលការណ៍ណែនាំ និងគោលនយោបាយនានា:**



Draft

១. គោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ ២០០៩

២. គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ឆ្នាំ២០១៣

៣. យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា

## ៤. ការពិពណ៌នាអំពីគម្រោង

ប្រភេទគម្រោង គឺជាវារីអគ្គិសនី និងមានប្រព័ន្ធបញ្ជូនចរន្តតង់ស្យុងខ្ពស់២៣០គ.វ៉។ ទំនប់នេះនឹងបង្កើតបានជាអាងទឹកដែល មានទំហំ ៨.៥៩១ហត ហើយនៅក្រោមទំនប់អាងទឹកនេះ ចម្ងាយប្រមាណ ៩,២គ.ម មានអាគារថាមពលដែលយកទឹកពីអាងនេះ តាមបំពង់ទូនេលបង្ហូរទឹកក្រោមដី មានសម្ពាធខ្ពស់ភ្ជាប់ទៅទួរប៊ីន២ (៤០ MW x ២) គឺមានកម្លាំងសរុប៨០MW។ ថាមពលអគ្គិសនីដែលផលិតបានត្រូវនាំតាមខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ពីអាគារថាមពលទៅបណ្តាញខ្សែ ២៣០kV ដែលតពីអនុស្ថានីយអូរសោម របស់ក្រុមហ៊ុនចិន ដែលមានប្រវែងសរុបប្រមាណ ៥គ.ម។ ដើម្បីសាងសង់គម្រោងនេះ ក្រុមហ៊ុនត្រូវការផ្ទៃដីសរុបទំហំ **៩.៣៥៥ហ.ត** ដែលស្ថិតនៅក្នុងភូមិស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ទីតាំងគម្រោងនេះស្ថិតក្នុងភូមិស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ត្រង់ចន្លោះខ្សែស្របទី ១១$^{0}$៣៩´ និង១២$^{0}$០២´ នៃរយៈទទឹងខាងជើង ខ្សែបណ្តោយ ១០៣$^{0}$០៣´ និង១០៣$^{0}$១៣´ នៃរយៈបណ្តោយខាងកើត។

វារីអគ្គិសនីនេះ គឺធ្វើអាងស្តុកទឹក១កន្លែង អាងនេះមានចំណុះស្តុកធម្មតា **១.២២៦,៥លានម$^{3}$** មានផ្ទៃលើ(នៅនីវ៉ូ ១៨០ម) ទំហំ ៨.៥៩១ហ.ត កំពស់ទឹកឡើងចុះធម្មតាគឺ ៦០ម។ វារីអគ្គិសនីនេះមានអនុភាពសរុប ៨០MW គឺផលិតអគ្គិសនី ៣៦៧,១២ GWh ក្នុងមួយឆ្នាំ នៅអាគារថាមពល ហើយបញ្ជូនអគ្គិសនីតាមខ្សែបញ្ជូនតង់ស្យុងខ្ពស់២៣០kV ពីអាគារថាមពល ដល់ទៅភ្ជាប់និងខ្សែបណ្តាញ២៣០គ.វ៉ ពោធិ៍សាត់-អូរសោម ដែលមានប្រវែងសរុបប្រមាណ ៥គ.ម (មាន ១៣ បង្គោលអគ្គិសនី)។

ផែនការរបស់ក្រុមហ៊ុនក្នុងការជ្រើសរើសបុគ្គលិក-កម្មករ ក្នុងពេលសាងសង់របស់គម្រោងទាំងមូល រួមទាំងការសាងសង់ ប្រព័ន្ធខ្សែបញ្ជូនចរន្ត និងអនុស្ថានីយផងដែលមានរយៈពេល៤ឆ្នាំ គិតទាំងការគ្រោងលំអិតនោះគឺ ត្រូវការមនុស្សរហូតទៅដល់ ៤០០នាក់ ក្នុងនោះបុគ្គលិក-កម្មករបរទេសចំនួន ១០០នាក់ និងពលករខ្មែរជុំវិញតំបន់គម្រោងចំនួន ៣០០នាក់។ ចំណែកឯ ពលកម្មសម្រាប់ការសាងសង់ប្រព័ន្ធខ្សែបញ្ជូនអគ្គិសនីពីអាគារថាមពល ភ្ជាប់ទៅ ខ្សែ២៣០គ.វ៉ អូរសោម-ពោធិ៍សាត់ ចំនួន៤០នាក់ ក្នុងនោះប្រជាពលរដ្ឋជុំវិញតំបន់គម្រោងចំនួន៣០នាក់ និងបុគ្គលិក-កម្មករបរទេសចំនួន ១០នាក់។ ចំនួនពលកម្មក្នុងកំឡុងពេលប្រតិបត្តិ និងថែទាំសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ គម្រោងផែនការរបស់ក្រុមហ៊ុន នឹងត្រូវការជ្រើសរើសបុគ្គលិក ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំរបស់គម្រោងសម្រាប់រយៈពេល ៣៥ឆ្នាំ មានចំនួន ៥០នាក់ ក្នុងនោះបុគ្គលិកខ្មែរ ចំនួន២៥នាក់ និងបុគ្គលិកបរទេស ចំនួន២៥នាក់។ បុគ្គលិកសម្រាប់គ្រប់គ្រងថែទាំប្រព័ន្ធខ្សែបញ្ជូនចរន្តពីអាគារថាមពលទៅបណ្តាញ ២៣០គ.វ៉ របស់ក្រុមហ៊ុនចិន ក្រុមហ៊ុនមានផែនការជ្រើសបុគ្គលិកក្នុងកំឡុងពេលប្រតិបត្តិ និងថែទាំរយៈពេល៣៥ឆ្នាំ ចំនួន១៣នាក់ ក្នុងនោះបុគ្គលិកខ្មែរ ចំនួន ០៦នាក់ និងបុគ្គលិកបរទេស ចំនួន៧នាក់។

តាមការគណនារបស់ក្រុមហ៊ុន SINOHYDRO គម្រោងនេះមានតម្លៃវិនិយោគសរុប **២៣២.២១០.០០០** (ពីររយសាមសិបពីរលាន ពីររយដប់ពាន់) ដុល្លារអាមេរិក និងទុនសម្រាប់កិច្ចការពារបរិស្ថានចំនួន ៨.៦៨៩.៣៧៦ (គិតទាំងតម្លៃដោះស្រាយផលប៉ះពាល់លើប្រជាពលរដ្ឋ) ផងដែរ។

## ៥. ស្ថានភាពធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គម្រោង

បរិមាណទឹកភ្លៀងធ្លាក់នៅក្នុងខេត្តពោធិ៍សាត់ គិតជាមធ្យមរយៈពេល១២ឆ្នាំ ពីឆ្នាំ ២០០០ ដល់ ២០១១ គឺ ១.៣៦៤.៩ មម (Return Period 12years)។ សីតុណ្ហភាពអតិបរមារយៈពេល ១៥ឆ្នាំ ខ្ពស់បំផុតមានកម្រិត ៣៧.១ $^{0}$C

នៅឆ្នាំ ២០០៤, សីតុណ្ហភាព អប្បបរមារយៈពេល១៥ឆ្នាំ ទាបបំផុតមានកម្រិត ១៨,៨ $^{o}$C នៅឆ្នាំ ២០០៩។ ល្បឿនខ្យល់បក់ជាមធ្យមក្នុងរយៈ ពេល១៥ឆ្នាំ គឺ៤,០ម/វិនាទី ហើយល្បឿនខ្យល់ដែលបក់ខ្លាំងជាងគេ នៅខែមិនា, កក្កដា, សីហា និង វិច្ឆិកា នៃឆ្នាំ១៩៩៦ និងខែកញ្ញា ឆ្នាំ១៩៩៧ ដែលមានល្បឿនជាម្យម ៧ម/វិនាទី។ សំណើមបរិយាកាសជាមធ្យមប្រចាំឆ្នាំ គិតក្នុងរយៈពេល១០ឆ្នាំ គឺ **៨១,៤%**។ បរិមាណរំហួតមធ្យមប្រចាំឆ្នាំនៃ រយៈពេល៥ឆ្នាំមាន **១.៤៣០,១៨មម**។ ការធ្វើតេស្តរកគុណភាពខ្យល់នៅក្នុងតំបន់គម្រោង បានបង្ហាញថាគុណភាពខ្យល់ស្ថិតនៅក្រោមកម្រិតស្តង់ដារ របស់ក្រសួងបរិស្ថាននៅឡើយ។ ចំពោះសំឡេងនិងរំញ័រ យោងតាមតារាង ៥-៩, ៥-១០ បានបង្ហាញថាពេលព្រឹកចាប់ពីម៉ោង ៦:០០ ដល់រសៀលម៉ោង ១៣:០០ សំឡេងជាមធ្យម ៥២,៧ dB គឺក្រោមស្តង់ដា (ស្តង់ដា៧0dB)។ ដូចគ្នាដែរ ចាប់ពីម៉ោង ១៤:០០ ល្ងាច ដល់ម៉ោង ១៨:០០ សំឡេងជាមធ្យម ៤៩,៨dB គឺក្រោមស្តង់ដា (ស្តង់ដា៦0dB)។ រីឯពេលយប់វិញ ចាប់ពីម៉ោង ២៣:០០ ដល់ពេល ភ្លឺម៉ោង ៥:០០ ក៏ស្ថិតនៅក្រោមស្តង់ដាផងដែរ សំឡេងជាមធ្យម គឺ៤៩,១dB(ស្តង់ដា៥0dB)។ ដោយឡែក នៅម៉ោង ៥:០០ ដល់ម៉ោង ៦ព្រឹក ក្នុងកំឡុងពេល វាស់មានរថយន្តដឹកទំនិញធំៗ ធ្វើចរាចរតាមផ្លូវនេះ បានធ្វើឱ្យសំឡេងមានការកើនឡើងចន្លោះ ៥០,៦០ ដេស៊ីប៊ែល (ស្តង់ដា៥0dB)។ យោងតាម តារាង៥-១១ បានបង្ហាញពីលទ្ធផលនៃការគណនាការប៉ាន់ស្មានធារទឹកជាមធ្យមប្រចាំឆ្នាំតាមទីតាំងទំនប់ គឺ៣,៩ ម$^{៣}$/វិនាទី។

តំបន់គម្រោងនេះ ដែលមានផ្ទៃដីសរុបចំនួន ៩.៣៥៥ហ.ត។ សរុបផ្ទៃដីព្រៃឈើដែលនឹងត្រូវប៉ះពាល់ចំនួន **៦,០០៧,២៤ ហ.ត** (ក្នុងនោះមានព្រៃសហគមន៍ ៣៥១,៦២ហ.ត)។ ថនិកសត្វសំខាន់ៗ ដែលរកឃើញក្នុងតំបន់គម្រោងនេះ មានចំនួន៤៦ប្រភេទ, ចំពោះសត្វស្លាបសំខាន់ៗដែលរកឃើញ មានក្នុងតំបន់គម្រោងមានចំនួន ១០១ប្រភេទ, ពពួកឧរង្គសត្វ និងកង្កែបមានចំនួន ៥៤ប្រភេទ, និងត្រីទឹកសាបមានចំនួន ៧៨ប្រភេទ។

Draft

គម្រោងនេះ មានផ្ទៃដីស្ថិតនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ចំនួន ៤.១៩៩,២ហ.ត (៤៥%) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ៣៩៩,៧ហ.ត (៤%) និងដែនជម្រកសត្វព្រៃភ្នំសំកុសចំនួន៤.៧៥៦,១ ហ.ត (៥១%) របស់ក្រសួងបរិស្ថាន ។

ការសាងសង់អាងនៃគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១នេះ បានធ្វើឱ្យប៉ះពាល់ផ្ទាល់ដល់ប្រជាពលរដ្ឋចំនួន០១ភូមិ គឺភូមិស្ទឹងថ្មី (ចំណុចអន្លង់ក្រូច ចំណុចអន្លង់ឃ្លូត ចំណុចអូរតាសួរ ចំណុចអូរធូង ចំណុចអូរស័ង្គសី ចំណុចស្វាយកោង និងអូរពងមាន់) ដែលមានប្រជាពលរដ្ឋប៉ះពាល់សរុបចំនួន <u>**៣៤៧គ្រួសារ**</u> ស្មើនិងចំនួនមនុស្សសរុប <u>**១,២៦៧នាក់**</u> (សិក្សាឆ្នាំ២០១៧)។ ចំពោះ៣៤៧គ្រួសារ នេះគឺប៉ះពាល់ដោយសារអាងតែប៉ុណ្ណោះ ចំពោះខ្សែបញ្ជូនចរន្ត២៣០គ.វ៉ និងហេដ្ឋារចនាសម្ព័ន្ធគម្រោងនេះដ៏ទៃទៀតមិនប៉ះពាល់ដល់ប្រជាពលរដ្ឋទេ។ ប្រជាពលរដ្ឋដែលប៉ះពាល់ ដោយសារគម្រោងនោះមានដើមឈើហូបផ្លែ និងដំណាំ សរុបចំនួន <u>**៧៨.៦១៨ដើម/គុម្ព ផ្ទះ៩២ខ្នង**</u> (មានផ្ទះ៩ប្រភេទ) និងមានសំណង់ផ្សេងៗដូចជា រោងឡាន/ម៉ូតូប្រក់ស័ង្កសី៥៨ម២, រោងបាយប្រក់ស័ង្កសី២៤ម២, ស្រះ៤.៦០៨,៤ម២, សំយ៉ាបប្រក់សង្ក័សី៩៦៥,៨ម២, សំយ៉ាបប្រក់ស្លឹក៧៣,៨០ម២, គ្រោងផ្ទះ១៧៧,៤ម២, ទ្រុងមាន់១៥, តូប៣, រោង៣៤, ជង្រុក២, អង់តែនការពាររន្ទះ១, ប្រព័ន្ធទុយោទឹក៤៥,៦៨៤ម, សូឡាបូមទឹក១, ជើងធុងទឹកបេតុង២ ប៉ះពាល់នឹងរុះរើចេញពីក្នុងអាងនេះផងដែរ។ នៅក្នុងចំណោម៣៤៧គ្រួសារ មាន៩៦គ្រួសារ ដែលប៉ះពាល់ធ្ងន់ធ្ងរជាគេ ដល់សេដ្ឋកិច្ចគ្រួសារ ដែលគម្រោង និងផ្លាស់ប្តូរទីលំនៅ ឬប្តូរដីកសិកម្ម ទៅកាន់ទីទួលមានសុវត្ថិភាព ស្ថិតនៅក្នុងភូមិស្ទឹងថ្មី ដែលមានកម្រិតនីវ៉ូលើសពី១៨០ម។ ជាងនេះទៅទៀត នៅក្នុងតំបន់អាងស្តុកទឹកនេះមានដីបម្រុងសម្រាប់យោធា ចំនួន ៣៥១,៦១ហ.ត នឹងត្រូវប៉ះពាល់ផងដែរ។

យោងតាមការចុះសិក្សាដោយផ្ទាល់នៅតំបន់គម្រោងគិតចាប់ពីអាងនៅឃុំប្រម៉ោយ(មើលផែនទី២) បានបង្ហាញឱ្យឃើញថា ដីដែលបានប្រើប្រាស់ដោយប្រជាពលរដ្ឋសរុបមានចំនួនប្រមាណ **២.៣២៩,២៥ ហ.ត** (ដីកសិកម្ម(ដីចំការ+ស្រែ), ដីបុស្ស, ដីលំនៅដ្ឋាន) ដែលប៉ះពាល់នៅក្នុងអាង។ ចំណែកឯកន្លែងសាងសង់ហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនី គឺមិនមានដីកាន់កាប់ដោយប្រជាពលរដ្ឋទេ។ ក្រុមការងារ SAWAC បានចែកតំបន់គម្រោងជា០៤ តំបន់គឺ: (តំបន់-១: ផ្ទៃអាង ៨.៥៩១,០០ហ.ត. តំបន់-២: ហេដ្ឋារចនាសម្ព័ន្ធ ៥៥៩.៩១ហ.ត, តំបន់-៣: ខ្សែបញ្ជូនចរន្ត២៣០គ.វ៉. ១៣.៦៤ហ.ត.

តំបន់-៤: កន្លែងតាំងទីលំនៅថ្មី ១៩០,៤៥ហ.ត) តំបន់គម្រោងមានផ្ទៃដីសរុបចំនួន៩.៣៥៥ហ.ត។ តំបន់នេះមិនគិតបញ្ចូលដីបំរុងសម្រាប់កន្លែងតាំងទីលំនៅថ្មីរបស់ពលរដ្ឋប៉ះពាល់បន្ថែម ៥០ហ.តទេ។

## ៦. ការចូលរួមប្រឹក្សា និង ពិគ្រោះយោបល់ពីសាធារណជននៅក្នុងតំបន់គម្រោង

គោលបំណងនៃការប្រឹក្សា

គោលបំណង នៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជន មានគោលបំណងដូចតទៅ:

- ធ្វើការផ្សព្វផ្សាយដល់សាធារណជន និងអ្នកដែលពាក់ព័ន្ធនឹងគម្រោងទាំងអស់ ឱ្យបានដឹងឮអំពីគោលបំណង និងដំណាក់កាលនៃការអនុវត្តគម្រោងនេះ ។
- កត់ត្រានូវមតិរិះគន់ សំណូមពរ បញ្ហាទំនាស់ និងរកវិធីសាស្ត្រកែលំអរផ្សេងៗរបស់ពួកគេទាំងនោះ ដើម្បីឱ្យគម្រោងនោះ ទទួលបានជោគជ័យ។
- ធ្វើការស្នើ ឬផ្តល់អនុសាសន៍ ដើម្បីដោះស្រាយទំនាស់ទាំងនោះដោយធ្វើការប្រជុំពិភាក្សាជាមួយអ្នកពាក់ព័ន្ធ និងមានការចូលរួមអំពីសំណាក់ អាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធក្នុងតំបន់គម្រោង ។

<u>លទ្ធផល នៃការប្រឹក្សា និងពិគ្រោះយោបល់ពីសាធារណជន</u>

**<u>ថ្នាក់កណ្តាល៖</u>**

- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អង្គការ CI ប្រចាំកម្ពុជា និងអង្គការ FFI ប្រចាំកម្ពុជា

**<u>ថ្នាក់ខេត្ត៖</u>**

- អភិបាល ខេត្តពោធិ៍សាត់
- នាយរងខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តពោធិ៍សាត់
- ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តពោធិ៍សាត់
- អនុ-ប្រធានមន្ទីរទេសចរណ៍ ខេត្តពោធិ៍សាត់
- អនុ-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពោធិ៍សាត់
- អនុ-ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តពោធិ៍សាត់
- អនុ-ប្រធានមន្ទីររ៉ែ និងថាមពល ខេត្តពោធិ៍សាត់
- ប្រធានមន្ទីរកសិកម្ម ខេត្តពោធិ៍សាត់
- នាយខណ្ឌរដ្ឋបាលជលផល ខេត្តពោធិ៍សាត់
- ប្រធានមន្ទីរបរិស្ថាន ខេត្តពោធិ៍សាត់
- អភិបាលស្រុកវាលវែង និងប្រធានឃុំប្រម៉ោយ
- ប្រធានភូមិ ប្រជាពលរដ្ឋ នៅចំណុចអន្លង់ក្រូច និងតាំងយ៉
- ក្រុមហ៊ុន China Northern Mining Co., Ltd រុករករ៉ែ ខេត្តពោធិ៍សាត់



Draft

# ៧. ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

## ៧.១ ហេតុប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយនៃហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនី

### ៧.១.១ ដំណាក់កាលរចនាគម្រោងមុនប្រតិបត្តិគម្រោង (មុនសាងសង់ និងសាងសង់)

**<u>ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន</u>**

- មានការប៉ះពាល់ដល់ប្រព័ន្ធជលសាស្រ្ត និងជីវៈចម្រុះក្នុងស្ទឹងពោធិ៍សាត់នៅផ្នែកខាងក្រោមកន្លែងសាងសង់ទំនប់នេះ ដល់អាគារថាមពល ដោយសារខ្វះទឹក និងមិនបានគិតគូរអំពីការធ្វើសំណង់បន្ថែម ដើម្បីបញ្ចេញទឹកមកខាងក្រោម តំបន់ទំនប់នេះឱ្យបានគ្រប់គ្រាន់។ ជាងនេះទៅទៀត ប៉ះពាល់គុណភាពទឹកស្ទឹងពោធិ៍សាត់ក្នុងពេលសាងសង់គម្រោង និងប្រតិបត្តិថែទាំគម្រោង។
- យោងតាមគម្រោងប្លង់សម្រាប់ការសាងសង់ទំនប់វារីអគ្គិសនីស្ទឹងពោធិ៍សាត់នេះ គឺពុំមានរចនាប្លង់គម្រោងសម្រាប់ឱ្យត្រីឆ្លងកាត់នោះទេ ដែលជាហេតុធ្វើឱ្យមានបញ្ហាប៉ះពាល់ដល់ចរាចរត្រី និងកន្ទាយនៅពេលដែលគម្រោងទាំងមូលនឹងសាងសង់ និងដំណើរការ។ តាមអន្លង់មួយចំនួន ដូចជាអន្លង់ជ្រៃ អន្លង់បឹងជាដើម មានក្រពើភ្នំរស់នៅដូចនេះពេលសាងសង់ និងតម្កល់ទឹកក្នុងអាងមានផលប៉ះពាល់ដល់ក្រពើរទាំងនេះ។
- ការគ្រោងរចនាគម្រោងដូចជា ប្លង់សម្រាប់សាងសង់ទំនប់ទឹក អាងទឹក អាគារថាមពល បំពង់ទូនែល និងហេដ្ឋារចនាសម្ព័ន្ធនានា របស់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ នេះស្ថិតនៅក្នុងតំបន់ព្រៃការពារ ដែលព្រៃបម្រុងទុកអចិន្ត្រៃយ៍ ៤.១៩៩,២ហ.ត គ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ឧទ្យានជាតិជួរភ្នំក្រវាញកណ្ដាល ៣៩៩,៧ ហ.ត និងដែនជម្រកសត្វព្រៃភ្នំសំកុស គ្រប់គ្រងដោយក្រសួងបរិស្ថាន ៤.៧៥៦,១ ហ.ត។
- ផ្ទៃដីគម្រោងមាន៩.៣៥៥ហ.ត ហើយក្នុងមានព្រៃឈើប៉ះពាល់តែ ៦,០០៧,២៤ហ.ត ក្នុងការសាសង់ហេដ្ឋារចនាគម្រោងវារីអគ្គិសនីនេះ។ ហេតុដូចច្នេះហើយ ក្រុមហ៊ុនត្រូវត្រៀមទាក់ទងជាមួយស្ថាប័ន មន្ទីរ និងក្រសួង ពាក់ព័ន្ធ សម្រាប់ធ្វើការកាប់សំអាតព្រៃឈើទាំងនោះចេញ។
- មានការប៉ះពាល់ដល់ការរស់នៅសត្វព្រៃខ្លះដែរ ដោយសារសកម្មភាពរបស់គម្រោង។
- ការអភិវឌ្ឍគម្រោងវារីអគ្គិសនីនេះ ត្រូវការផ្ទៃដីសរុប ៩.៣៥៥ហ.ត ដែលក្រុមការងារ SAWAC ចែកជា៤តំបន់គឺ តំបន់ ១ ជាតំបន់អាង ដែលមានផ្ទៃដី ៨.៥៩១ហ.ត ក្នុងនោះមានការប៉ះពាល់ការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋចំនួន ២.៣២៩,២៥ ហ.ត (ដីកសិកម្ម ៩៣២,១២ហ.ត ដីបុស្ស ១.០៦៨,៣៩ ហ.ត និង ដីលំនៅដ្ឋាន ៣៨,៤៤ ហ.ត) ជារបស់ ៣៤៧គ្រួសារ។ តំបន់១នេះ ក៏មានការប៉ះពាល់ដីសហគមន៍តំបន់ការពារធម្មជាតិស្រែពាំង ៣៤១,៧៣ហ.ត និងដីសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មី ៩,៨៩ហ.ត ផងដែរ។ ចំណែកឯ តំបន់២ តំបន់៣ និងតំបន់៤ មិនការប៉ះពាល់ដល់ដីប្រជាពលរដ្ឋទេ។ គម្រោងនេះក៏មានការប៉ះពាល់ដល់សម្បត្តិសាធារណៈដូចជា៖ ប៉ះផ្លូវរទេះ(ផ្លូវលំចាស់)ចេញចូលទៅចំណុចអន្លង់ក្រូច និងអន្លង់យូតប្រមាណ ១៦គ.ម។
- អាចនឹងមានជនឆ្លៀតឱកាសបំផុសប្រជាជនឱ្យចាប់ដីនៅក្នុងតំបន់គម្រោង ដែលជាព្រៃការពាររបស់ផ្នែករដ្ឋបាលព្រៃឈើ និងដីដែនជម្រកសត្វព្រៃធ្វើឱ្យបាត់បង់ធនធានព្រៃឈើកាន់តែច្រើន។
- អាចមានការប៉ះពាល់ និងគ្រោះថ្នាក់ដល់អ្នកសិក្សាឬធ្វើឱ្យស្ទះការងារសិក្សាប្លង់រចនាគម្រោង ដោយសារមិនមានផ្លូវដឹកជញ្ជូនច្បាស់លាស់សម្រាប់គម្រោងនេះ ដែលមានចំណោតខ្លាំង ហើយឆ្លងកាត់ជ្រោះ ដែលមានផ្ទាំងថ្មកន្លែងខ្លះជាល្បាក់ ជ្រៅពុំអាចឆ្លងកាត់បាន។
- ការគ្រោងគម្រោងមិនត្រឹមត្រូវតាមបច្ចេកទេស បង្កហានិភ័យខ្ពស់ដូចជា បាក់ទំនប់ រអិលបាក់ភ្នំនាំឱ្យខូចខាតទ្រព្យសម្បត្តិ និងអាយុជីវិតរបស់ប្រជាពលរដ្ឋជាដើម។

Draft

**វិធានការកាត់បន្ថយ**

- នៅខាងក្រោមតំបន់ទំនប់ដល់អាគារថាមពល តាមដងស្ទឹងមានចម្ងាយប្រមាណ៩,២គ.ម។ នៅតំបន់នេះក្រុមហ៊ុននឹងធ្វើការបញ្ចេញទឹកពីអាងចំនួន ១,៣ម³/វិនាទី ឥតដាច់ទាំងប្រាំង និងវស្សា។
- ត្រូវចាត់វិធានការការពារការហូរច្រោះនៃជញ្ជាំង ដី ទួលឬភ្នំ ការចាក់ថ្ម និងដីស្អុយនិងសំអាតព្រៃបាតអាង រួមទាំងប្រមូលឈើអណ្តែតទឹក ហើយត្រូវមានការគ្រប់គ្រងសំណល់រឹង-រាវគ្រប់ប្រភេទឱ្យបានល្អតាមបច្ចេកទេស ត្រឹមត្រូវក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិថែទាំគម្រោងផងដែរ។
- ត្រូវមានវិធានការដើម្បីជំនួសសំណង់សិល្បការសម្រាប់ឱ្យត្រីឆ្លងកាត់នេះ ដោយធ្វើការព្រលែងកូនត្រី (រើសពូជក្នុងតំបន់) និងមូនិធិសម្រាប់សង្គ្រោះក្រពើរភ្នំ រួចធ្វើការព្រលែងត្រីទាំងនេះចូលក្នុងអូរស្ទឹងធម្មជាតិ ដែលមានលក្ខណៈទីជម្រកសមស្របប្រហាក់ប្រហែលគ្នា ដោយធ្វើការសហការណ៍ជាមួយរដ្ឋបាលជលផល និងរដ្ឋបាលព្រៃឈើ។
- ក្រុមហ៊ុនបានគិតគូរយ៉ាងហ្មត់ចត់ អំពីករណីនៃការគ្រោងគម្រោងនេះ ដោយធ្វើការប្រៀបធៀបពករណីទៅនឹងតម្លៃសេដ្ឋកិច្ចរួមទាំងបរិស្ថាន និងគ្រោងហេដ្ឋារចនាសម្ព័ន្ធគម្រោងមួយចំនួនដូចជាការជ្រើសយកវិធីចោះរន្ធទូនែលក្រោមដី ដោយមិនប្រើការជីកប្រឡាយនាំទឹកដែលធ្វើឱ្យបាត់បង់គម្របព្រៃឈើច្រើន។ ត្រូវដាក់បញ្ហាឱ្យកាប់តែព្រៃក្នុងកន្លែងសាងសង់ហេដ្ឋាចេនាសម្ព័ន្ធគម្រោងជាក់ស្តែងប៉ុណ្ណោះ ទោះបីជាខ្លួនបានគ្រោងព្រំប្រទល់តំបន់នោះក៏ដោយ (មើលផែនទី៦ ក្នុងឧបសម្ព័ន្ធ ៨)។
- ក្រុមហ៊ុន ត្រូវសុំការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីកាប់ឈើក្នុងតំបន់ព្រៃការពារព្រៃបម្រុងទុកអចិន្ត្រៃយ៍ ២.៩៥៩,៥៣ហ.ត និងត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថាន កាប់សំអាតឈើក្នុងដែនជម្រកសត្វព្រៃភ្នំសំកុស ចំនួន៤.៧៥៦,១ហ.ត និងឧទ្យាជាតិជួរភ្នំក្រវាញកណ្តាលចំនួន ៣៩៩,៧ហ.ត ក្នុងដំណាក់កាលសាងសង់គម្រោង។
- គ្រោងថវិកាការពារបរិស្ថានសរុបចំនួន ៨,៦៨៩ លានដុល្លារអាមេរិក (ក្នុងនោះមានថវិកាសម្រាប់ដោះស្រាយផលប៉ះពាល់ប្រជាពលរដ្ឋក្នុងអាងផងដែរ) ដើម្បីការពារបរិស្ថាន រួមទាំងមានមូនិធិបរិស្ថាន និងសង្គម ដើម្បីស្តារ និងសង្គ្រោះមច្ឆជាតិងាយរងគ្រោះថ្នាក់ និងសង្គ្រោះក្រពើភ្នំទៀតផងដែរ។ ក្នុងនោះត្រៀមថវិកាចំនួន ៦.៨៣៣.០១៦ ដុល្លារអាមេរិកសម្រាប់សំណង និងការអភិវឌ្ឍតំបន់ថ្មីសម្រាប់អ្នកប៉ះពាល់ ដោយសារគម្រោងនេះ៣៤៧គ្រួសារ។ ចំពោះសំណង មាន២ករណី ករណីទី១គឺ សំណងជាដី ២ហ.ត ក្នុង១គ្រួសារ (គិតតាមសមាមាត្រ នៃចំនួនដីរបស់គេ បើដីរបស់គេលើសពី ២ហ.ត ទៅ ដីនៅសល់សំណងជាប្រាក់ បើដីរបស់គាត់តិចជាង ២ហ.ត សំណងតាមដីដែលមាននោះ) ករណីទី១នេះ មាន ១១៩គ្រួសារ។ ករណីទី២ សំណងជាប្រាក់មាន ៥០គ្រួសារ ។ បន្ថែមទៀតម្ចាស់គម្រោង និងសាងសង់ផ្ទះថ្មីជូនអ្នកក្រីក្រ ១០គ្រួសារផងដែរ។
- ក្រុមហ៊ុនធ្វើការសហការណ៍ជាមួយអាជ្ញាធរមានសមត្ថកិច្ច រដ្ឋបាលព្រៃឈើ ដែនជម្រកសូព្រៃភ្នំសំកុស ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងអង្គការ CI ដើម្បីចាត់វិធានការទប់ស្កាត់ និងបង្កើនកម្លាំងការពារតំបន់នេះ។
- ក្រុមហ៊ុនរកអ្នកនាំផ្លូវរស់នៅក្បែរតំបន់គម្រោង ដែលស្គាល់ភូមិសាស្ត្រច្បាស់លាស់ដែលធ្លាប់ចេញចូលតំបន់នេះ។
- ត្រូវរកក្រុមហ៊ុនធានារ៉ាប់រងអន្តរជាតិ ដើម្បីធ្វើការធានារ៉ាប់រងគុណភាពសំណង់ ដែលពាក់ព័ន្ធនឹងវារីអគ្គិសនីនេះយ៉ាងហោចណាស់ឱ្យបានក្នុងរយៈពេល ៩០ឆ្នាំយ៉ាងតិចដែរ។

៧.១.២ ដំណាក់កាលសាងសង់គម្រោង

**ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន**

- បណ្តាលឱ្យប្រែប្រួលសណ្ឋានដី និងឋានលេខាក្នុងទីតាំងគម្រោង ដោយសារសកម្មភាព ការឈូសឆាយ និងពង្រាបដីស្រទាប់លើ ដែលមានគម្របព្រៃដើម្បីធ្វើហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង។
- បង្កឱ្យប៉ះពាល់ដល់បរិមាណធារទឹករបស់ស្ទឹងពោធិ៍សាត់ ដោយសារការទប់ទំនប់កាត់ស្ទឹងពោធិ៍សាត់ ដើម្បីធ្វើអាងតម្កល់ទឹក។ នៅខាងក្រោមតំបន់គម្រោង មានសំណង់ធារាសាស្ត្រស្ទាក់ទឹកបើកន្លែងគាត់ស្ទឹងពោធិ៍សាត់ គឺដំណាក់

ឈើក្រំ (គ្រោងសាងសង់ ឆ្នាំ២០១៧) ដំណាក់អំពិល និងចារឹក ដែលយកទឹកទៅស្រោចស្រប់ដីកសិកម្មក្នុងខេត្តពោធិ៍សាត់ និងបាត់ដំបង។

- អាចមានការហូរច្រោះដីដោយសារការឈូសឆាយដីគម្របព្រៃឈើ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង។
- អាចបង្កឡើងដោយសារការបំផ្ទុះផ្ទាំងថ្មនៅការដ្ឋានធ្វើទំនប់ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋដែលរស់នៅជុំវិញ ដោយស្ទះផ្លូវចេញចូល និងសំណង់ ឬប៉ះពាល់ដល់សុវត្ថិភាពកម្មករ ដូចជាការរញ្ជួយបាក់ផ្ទាំងថ្មជាដើម ។ល។ ការរញ្ជួយ ដោយសារការដឹកសម្ភារសំណង់ធ្ងន់ៗ (ថ្ម ខ្សាច់ ប្រើគ្រឿងរំញ័រក្នុងការបង្ហាប់បេតុង និងដឹកដុំទូរប៊ីនភ្លើង) ក្នុងការសាងសង់ទំនប់ សាងសង់រន្ធទូនេល អាគារថាមពលជាដើម។
- ប៉ះពាល់គុណភាពទឹកស្ទឹងពោធិ៍សាត់ដោយសារសំណល់រឹង-រាវ មកពីការបោះចោលសំណល់ផ្ទះបាយ បង្គន់ដែលសង់គ្មានបច្ចេកទេស និងការខ្វះខាតបង្គន់ អនាម័យគ្រប់គ្រាន់ សម្រាប់បុគ្គលិកកម្មករគម្រោង និងការបោះសំណល់សម្ភារសំណង់ ដោយបុគ្គលិក-កម្មករក្រុមហ៊ុន (ការហៀរ ឬលេចជាតិប្រេង ពីគ្រឿងចក្ររថយន្ត បារ ស៊ីម៉ងត៍ បារ ឬស្បោងច្រកសារធាតុគីមី ផ្សេងទៀត។ល។)
- បំពុលខ្យល់ ដោយសារការដុតព្រៃឈើដើម្បីសំអាតការដ្ឋាន និងផ្សែង ដែលបំភាយចេញពីគ្រឿងចក្រសាងសង់ រថយន្តដឹកជញ្ជូនសម្ភារ និងការបំផ្ទុះសម្រាប់ការងារសាងសង់របស់គម្រោង។
- បំពុលដីដោយសារការចាក់ដីស្អុយ ឬសំណល់ថ្ម ដែលដឹកចេញពីតំបន់គម្រោងនោះ ក៏អាចនឹងបង្កឱ្យមានផលប៉ះពាល់ ដល់ស្រទាប់ ដីខាងលើ និងលុបអន្លង់នានា តាមពោះស្ទឹង ដែលជាជម្រកមច្ឆជាតិផងដែរ។
- អាចប៉ះពាល់ដល់ផ្លូវចេញចូលរបស់មច្ឆជាតិ និងជីវសាស្ត្រនៅក្នុងទឹក ដោយសារក្រុមហ៊ុនទប់ទំនប់បណ្តោះអាសន្ន កាត់ស្ទឹងពោធិ៍សាត់ ដើម្បីសាងសង់ទំនប់វារីអគ្គិសនីនេះ។ ម៉្យាងវិញទៀត ក្រុមហ៊ុនគ្មានគម្រោងសាងសង់ជណ្តើរត្រី ឬសំណង់ដែលសម្រាប់ឱ្យត្រីឆ្លងកាត់ពីខាងក្រោមទៅតំបន់ខាងលើទំនប់បានទេ។
- គម្រោងនេះមានផ្ទៃដីសរុប ៩.៣៥៥ហ.ត ហើយក្នុងនោះមានៈ ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ៤.១៩៩,២ហ.ត ក្នុងនោះប៉ះពាល់ព្រៃឈើ ២.៩៥៩,៥៣ហ.ត (ទំនប់, ផ្ទៃអាងមួយចំនួន, អាគារថាមពល និងតំបន់ហេដ្ឋារចនា សម្ព័ន្ធនានារបស់គម្រោង), ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល ៣៩៩,៧ហ.ត ក្នុងនោះប៉ះពាល់ដីព្រៃឈើ ១៣៧,១៤ហ.ត និងប៉ះពាល់ដែនជម្រកសត្វព្រៃភ្នំសំកុស ៤.៧៥៦,១ហ.ត ក្នុងនោះប៉ះពាល់ដីព្រៃឈើ២.៩១០,៧៥ហ.ត ដែលនឹងបង្កឱ្យមានផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់នេះយ៉ាងខ្លាំង។
- គម្រោងនេះ ប៉ះពាល់ដល់ផ្ទៃដីព្រៃឈើសរុប ៦,០០៧,២៤ហ.ត ក្នុងនោះមាន ព្រៃស្រោង ៨៦៥,៤៩ហ.ត (មានឈើ ១១៦ប្រភេទ) ព្រៃពាក់កណ្តាលស្រោង៨៥០,២៥ហ.ត(មានឈើ៩៣ប្រភេទ) និងព្រៃល្បោះ៤.២៩១,៥ហ.ត (មានឈើ ១០២ប្រភេទ)។
- តំបន់គម្រោងនេះ មានសត្វព្រៃជាច្រើនប្រភេទដែលរស់នៅ ហើយប្រភេទសត្វមួយចំនួនកំពុងត្រូវបានធ្វើការអភិរក្សដោយស្ថាប័នមានសមត្ថកិច្ច។ សត្វព្រៃ ទាំងនេះមានដូចជាៈ ថនិកសត្វចំនួន៤៥ប្រភេទ បក្សី១០១ប្រភេទ ឧរង្គសត្វ និង ថលជលិកសត្វ ៥៤ប្រភេទ និងត្រីទឹកសាប៧៨ប្រភេទ ក្នុងស្ទឹងពោធិ៍សាត់។
- ការសាងសង់គម្រោងនេះ ប៉ះពាល់ការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋសរុប ចំនួន២.៣២៩,២៥ហ.ត ដែលកាន់កាប់ដោយ ៣៤៧គ្រួសារ ក្នុងនោះមានដីកសិកម្ម (ស្រែ និងចំការ) ចំនួន ៩៣២,១២ហ.ត. ដីលំនៅដ្ឋាន ៣៨,៤៤ហ.ត. និងដីបុស្ស ១.០៦៨,៣៩ហ.ត។
- មានប្រជាជនចំនួន ៣៤៧គ្រួសារ នឹងរងការប៉ះពាល់ដោយសារការអភិវឌ្ឍគម្រោងវារីអគ្គិសនីនេះ ក្នុងនោះមានប្រជាជន ៩៦គ្រួសារនឹងត្រូវប៉ះពាល់ធ្ងន់ធ្ងរជាងគេដោយសារពួកគេបាត់បងដីកសិកម្ម នាំឱ្យបាត់បងចំណូលគ្រួសាររបស់គាត់។
- បរិមាណធារទឹករបស់ស្ទឹងពោធិ៍សាត់អាចនឹងប៉ះពាល់ ដោយសារការទប់ទំនប់កាត់ស្ទឹងពោធិ៍សាត់ ដើម្បីធ្វើអាងតម្កល់ទឹកដែលជាហេតុបង្កឱ្យមានការប្រែប្រួលប្រព័ន្ធអេកូឡូស៊ី និងប្រព័ន្ធលំហូរទឹកផ្សេងទៀត ដែលបែកចេញពីស្ទឹង នៅក្រោមទំនប់ ជាពិសេសអាចប៉ះពាល់ដល់ប្រព័ន្ធធារាសាស្ត្រដំណាក់ឈើក្រំ ដំណាក់អំពិល និងចារឹក ដោយខ្វះទឹកខណៈដែលទប់ស្ទឹងនេះដើម្បីសាងសង់ទំនប់មេ។ គុណភាពទឹក ក៏អាចនឹងប៉ះពាល់ផងដែរ ដោយ

Draft

សារសកម្មភាពសាងសង់ ដែលធ្វើឱ្យទឹកស្ទឹងមានការបំពុល ជាហេតុបង្កឱ្យកម្មករ និងប្រជាពលរដ្ឋ ដែលមករកអនុផលព្រៃឈើមិនអាចប្រើទឹកនេះបាន។

- គម្រោងនេះក៏ធ្វើឱ្យប៉ះពាល់ដល់សហគមន៍តំបន់ការពារធម្មជាតិ ២ គឺសហគមន៍តំបន់ការពារធម្មជាតិស្រែពាំង ចំនួន ៣៤១,៤១ ហ.ត និងសហគមន៍តំបន់ការពារធម្មជាតិស្ទឹងថ្មី ចំនួន ៩,៨៩ ហ.ត។
- ធ្វើឱ្យប៉ះពាល់ដល់ផ្លូវជាតិលេខ៥៥ មានស្ពាន និងលូជាច្រើន ដែលចេញពីក្រុងពោធិ៍សាត់ ទៅប្រមោយទីរួមស្រុកវាលវែង (ឆ្នាំ២០១៧ ផ្លូវនេះបានសាងសង់ចាក់កៅស៊ូរួចហើយ) ដោយសារសកម្មភាពសាងសង់គម្រោង និងការដឹកជញ្ជូនសម្ភារបរិក្ខារ គ្រឿងចក្រចូលទៅទីតាំងគម្រោងបង្កឱ្យមានការស្រុត ឬខូចផ្លូវ ការបាក់ស្ពាន បាក់លូ ឬគ្រោះថ្នាក់ចរាចរលើទ្រូងផ្លូវ ដែលមានចំណោទឡើងទូល និងផ្លូវកោង ជាដើម។ ល។

**<u>វិធានការកាត់បន្ថយ</u>**

- ធ្វើការសាងសង់ធំៗនៅរដូវប្រាំងដើម្បីទប់ស្កាត់ការហូរច្រោះ ដែលនាំឱ្យខូចសណ្ឋានដីនៅរដូវវស្សា។ នៅរដូវវស្សាក្រុមហ៊ុន ធ្វើការសាងសង់ទំនប់ ដោយធ្វើផែនការសាងសង់ប្រចាំខែច្បាស់លាស់ ដូចជាការសង់ជញ្ជាំងបេតុងដែលស្រោបព័ទ្ធជុំវិញទំនប់ជាមុនឱ្យបានខ្ពស់ជាងកំពស់ថ្មដែលត្រូវចាក់ក្នុងរយៈ១ខែ ដើម្បីជៀសវាងការហូរច្រោះកំទេចថ្មចូលស្ទឹងជាដើម។
- បានសាងសង់ផ្លូវទឹកបង្វៀងការដ្ឋាន ដើម្បីផ្តល់ទឹកមកខ្សែទឹកខាងក្រោមឱ្យបានជាធម្មតាវិញ។
- ត្រូវពង្រាបដី ឬថ្មដែលចាក់ចោល ដោយយកដីមានជីជាតិលប់ពីលើរួចដាំដើមឈើឡើងវិញក្នុងតំបន់នេះដោយ ធ្វើការសហការណ៍ជាមួយផ្នែករដ្ឋបាលព្រៃឈើ ពោធិ៍សាត់។
- ក្រុមការងាររបស់ក្រុមហ៊ុនបានកំណត់តំបន់គ្រោះថ្នាក់ ដោយសារការផ្ទុះនេះច្បាស់លាស់រួចដាក់ផ្លាកសញ្ញាគ្រោះថ្នាក់នៅតាមព្រំប្រទល់តំបន់នេះ ដើម្បីឱ្យកម្មករនិយោជិតគម្រោង និងប្រជាពលរដ្ឋងាយឃើញ និងស្គាល់។
- សាងសង់អាងសិបទិកតាមបច្ចេកទេសសម្រាប់ទឹកកខ្វក់ចេញពីការិយាល័យបន្ទប់ទឹក បង្គន់ ផ្ទះបុគ្គលិក ដែលស្នាក់នៅបណ្តោះអាសន្នក្នុងពេលសាងសង់គម្រោង។
- ក្រុមហ៊ុនមិនដុតព្រៃឈើទាំងអស់នៃតំបន់នឹងត្រូវលិចនោះទេ គឺក្រុមហ៊ុនធ្វើការសហការណ៍ជាមួយរដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន ដើម្បីធ្វើការសំអាតព្រៃក្នុងតំបន់ដែលនឹងត្រូវលិចដូចជាៈ ក្រសួងអាចលក់ឈើឱ្យក្រុមហ៊ុនផ្សេង ដែលក្រុមហ៊ុននេះ ត្រូវកែច្នៃឈើទាំងនោះឱ្យអស់លទ្ធភាព ដែលអាចធ្វើទៅបាន ហើយបានថវិកាចូលរដ្ឋថែមទៀតផង។
- ក្រុមហ៊ុនត្រូវពង្រាបដី ឬថ្មដែលចាក់ចោលដោយយកដីមានជីជាតិលប់ពីលើរួចដាំដើមឈើឡើងវិញក្នុងតំបន់នេះដោយធ្វើការសហការណ៍ជាមួយរដ្ឋបាលព្រៃឈើ។
- ក្រុមហ៊ុនបានគ្រោងសាងសង់ចោះរូងកាត់ភ្នំធ្វើជាផ្លូវទឹកបង្វៀងការដ្ឋានទំនប់ ដោយមានជំរាលបាតមិនចោទ ដើម្បីបង្កភាពងាយស្រួលដល់ការធ្វើចរាចរនៃជីវសាស្ត្រក្នុងទឹកពីផ្នែកខាងក្រោមការដ្ឋានទៅផ្នែកខាងលើការដ្ឋានបាន។
- ក្រុមហ៊ុន បង់មូលនិធិបរិស្ថាន និងសង្គម ដល់ក្រសួងបរិស្ថានសម្រាប់១ជីវិតគម្រោង (៣៥ឆ្នាំ) ដែលមានវដ្ត១រយៈពេល១០ឆ្នាំម្តង។ ចំនួនថវិកាសរុប សម្រាប់មូលនិធិបរិស្ថាន និងសង្គមនេះមាន ៨២៦.៤៨០ដុល្លារអាមេរិក សម្រាប់ការស្តារធនធានបរិស្ថានដែលនឹងត្រូវប៉ះពាល់ដោយសារគម្រោង និងចូលរួមអភិវឌ្ឍន៍ភូមិ ឃុំក្នុង/ក្បែរតំបន់គម្រោងផងដែរ។
- ក្រុមហ៊ុនត្រូវធានាមិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដែលមានបង្ហាញនៅក្នុងប្លង់រចនាគម្រោង លំអិតឡើយ។ ម៉្យាងទៀតក្រុមហ៊ុនត្រូវរក្សាទុកព្រៃនៅតំបន់នេះចំនួន ៤៣១,១៧ហ.ត ដោយមិនឱ្យឈូសឆាយ និងកាប់ទាំងស្រុងនោះទេ ពោលគឺសំអាតនៅកន្លែង ដែលសាងសង់សំណង់ជាក់ស្តែងប៉ុណ្ណោះ។
- ត្រៀមថវិកាចំនួន ៦.៨៣៣.០១៦ដុល្លារអាមេរិក សម្រាប់សំណង និងការអភិវឌ្ឍតំបន់ថ្មីសម្រាប់អ្នកប៉ះពាល់ដោយសារគម្រោងនេះ ៣៤៧គ្រួសារ។ ចំពោះសំណង មាន៣ករណីគឺ ករណីទី១ សំណងជាដី ២ហ.ត ក្នុង១គ្រួសារ (គិតតាមសមាត្រនៃចំនួនដីរបស់គេ បើដីរបស់គេលើសពី២ហ.តទៅ ដីនៅសល់សំណងជាប្រាក់ បើដីរបស់

គាត់តិចជាង២ហ.ត សំណង២ហ.ត) ករណីទី១នេះមាន៧៤គ្រួសារ។ ករណីទី២គឺសំណងជាប្រាក់មាន២៨០គ្រួសារ។ ករណីទី៣ គឺសំណងជាផ្ទះ មាន២៤ គ្រួសារ (ផ្ទះប៉ះពាល់សរុប ៩២ខ្នង ជារបស់ ៧៨គ្រួសារ)។ ***សម្គាល់:*** *ករណីសំណងជាដី ផ្អែកលើលក្ខណៈវិនិច្ឆ័យ ៣ គឺ ១)សំណូមពរ របស់អ្នកប៉ះពាល់ទាំងនោះ ២) មេគ្រួសារជាជនងាយរងគ្រោះ (មេម៉ាយ ចាស់ជរា អសមត្ថភាពការងារ មានប័ណ្ណក្រីក្រ និងជនជាតិដើមភាគតិច) ៣) ប៉ះពាល់ដី កសិកម្ម ចាស់ពី៥០% រហូតដល់ ១០០%។ វិនិច្ឆ័យផ្តល់ដីគឺសមាមាត្រ ២/៣។ ចំណែកឯ សំណងជាផ្ទះ ផ្តល់អត្ថិភាពឱ្យ មេគ្រួសារជាជនងាយរងគ្រោះ រួមទាំងមាន៣លក្ខណៈវិនិច្ឆ័យផងដែរ។ឧទាហរណ៍៖ គ្រួសារ ឈ្មោះ* ***ក*** *ជាជនងាយរងគ្រោះដែលមានផ្ទះប៉ះពាល់ គាត់ត្រូវទទួលបានសំណងជាផ្ទះ ៨០ម² តាមជម្រើសរបស់គាត់ (ផ្ទះសំណងមាន៣ ជម្រើស) ទោះជាផ្ទះរបស់គាត់ តូច ប្រក់ស្លឹកក៏ដោយ។ ជាងនេះទៀត បើគ្រួសារអ្នកប៉ះពាល់ ស្ថិតក្នុង ២ចំណុច នៃ៣លក្ខណៈវិនិច្ឆ័យខាងលើក៏ត្រូវផ្តល់សំណងជាផ្ទះផងដែរ។*

- ក្រុមហ៊ុនត្រូវធ្វើផែនការបំលាស់ប្តូរលំនៅដ្ឋាន របស់ប្រជាពលរដ្ឋក្នុងតំបន់១(តំបន់អាងទឹក) និងបង្កើតតំបន់តាំងទីលំនៅថ្មីឱ្យបានមុនយ៉ាងតិច១ឆ្នាំ មុននឹងធ្វើការបិទទ្វារទឹកបំពេញអាងនេះ។ ចំពោះប្រជាជន៩៦គ្រួសារ ដែលបាត់បង់ ចំណូលនោះ ក្រុមហ៊ុនគ្រោងថវិកាក្នុង១គ្រួសារ ៤១៥ដុល្លារអាមេរិក/គ្រួសារ សម្រាប់បង្កើតកម្មវិធីស្តារចំណូល ដូចជា ផ្តល់ពូជដំណាំ (ការបណ្តុះកូនឈើហូបផ្លែ) ពូជសត្វចិញ្ចឹមជាដើម ដើម្បីជំនួយឱ្យពួកគាត់អាចធ្វើការស្តារចំណូលឡើងវិញក្នុងរយៈពេលអន្តរកាល១ឆ្នាំ ពេលដែលគាត់រើទៅនៅកន្លែងតាំងទីលំថ្មីនោះ (ការគ្រោងតម្លៃលំអិតមើលក្នុង តារាង ៩-៣)។
- ក្រុមហ៊ុនគ្រោងចោះជារូងទូនេល ដើម្បីធ្វើការរំដោះទឹកមកតំបន់ខាងក្រោមគម្រោង មិនឱ្យមានការប៉ះពាល់ដល់លំហូរធារទឹកស្ទឹងនេះទេក្នុងពេលសាងសង់គម្រោងនេះ។
- ក្រុមហ៊ុនត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យលទ្ធភាពសុំអនុបយោគដីព្រៃរបស់រដ្ឋ ដើម្បីការតាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋពាល់ដោយសារគម្រោង។

៧.១.៣ ដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង

**ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន**

- ប៉ះពាល់ដល់ប្រព័ន្ធជលសាស្ត្រនៃស្ទឹងពោធិ៍សាត់ និងខ្សែទឹកខាងក្រោម ដោយសារការបង្ខាំងទឹក ដើម្បីស្តុកទឹកទុកក្នុងអាងឱ្យបានកម្លាំងគ្រប់គ្រាន់សម្រាប់អូសទួរប៊ីនភ្លើងកម្លាំងសរុប ៨០មេហ្គាវ៉ាត់ និងការបញ្ចេញទឹកពីទំនប់មិនគ្រប់គ្រាន់ធ្វើឱ្យប៉ះពាល់ដល់របបទឹករបស់ស្ទឹងពោធិ៍សាត់ ដែលស្ថិតនៅចន្លោះទំនប់ និងអាគារថាមពល (ចម្ងាយប្រមាណ ៩,២គ.ម បើវាស់តាមផ្លូវទឹក)។
- ម្យ៉ាងទៀត ការបើកបិទ ទឹកសម្រាប់ដំណើរការផលិតអគ្គិសនីនៅរដូវប្រាំង ដែលមានធារទឹកពី ៤០ ដល់ ៨០ ម³/វិនាទី ដែលមុនការសាងសង់គម្រោងមានតែ ០,៦ ទៅ ១,៦ម³/វិន. (ជាលក្ខណៈធម្មជាតិ) នាំឱ្យមានការប៉ះពាល់ ដល់ប្រជាពលរដ្ឋ អ្នកនេសាទ ឧបករណ៍នានា ដែលមាននៅក្នុងពោះស្ទឹង។ ជួនកាលអាចបណ្តាលឱ្យលិចតំបន់មួយចំនួននៅខាងក្រោម ដោយសារធារទឹក ៨០ ម³/វិនាទី នេះផងដែរ។
- អាចមានការហូរច្រោះ រួចបណ្តាលឱ្យបាក់ដីនៅតាមជញ្ជាំងដីតាមដងផ្លូវ កន្លែងចាក់ជាគំនរថ្ម និងដីចោលធ្វើឱ្យដីបាក់នេះស្ទះផ្លូវ ឬស្ទះចរន្តទឹក ឬរាក់ផ្លូវទឹក ឬធ្វើឱ្យដីដែលហូរច្រោះទាំងនេះ ទៅគ្របពីលើដីមានឈើដុះធ្វើឱ្យបាត់បង់ជីជាតិដី និងបណ្តាលឱ្យដើមឈើទាំងនោះងាប់ដោយសារតែគល់វាត្រូវដីគ្របសង្កត់ជាដើម។ល។
- អាចនឹងប៉ះពាល់គុណភាពទឹកលើដី ដោយសារការបញ្ចេញសំណល់រាវ-រឹងពី កន្លែងរស់នៅរបស់បុគ្គលិកកម្មករគម្រោង បណ្តាលមកពីគុណភាពសំអាត របស់អាងសិបទិកបាត់បង់ និងការធ្វេសប្រហែសក្នុងការគ្រប់គ្រងសំណល់រឹងគ្រប់ប្រភេទ ដែលធ្លាក់ចូលក្នុងប្រព័ន្ធផ្លូវទឹកក្នុងតំបន់ធ្វើឱ្យបំពុលទឹកនៃប្រភពទាំងនោះទៀតផង។
- នៅស្ទឹងពោធិ៍សាត់ត្រង់តំបន់គម្រោងមានត្រី ៧៨ប្រភេទ។ ការបិទទ្វារទឹក ដើម្បីតម្កល់ទឹកក្នុងអាងអាចប៉ះពាល់ដល់ប្រភេទវារីសត្វងាយរងគ្រោះថ្នាក់មួយចំនួនដូចជា អណ្តើកដំបូក ឬអណ្តើកព្រិច អណ្តើកទឹក កន្ធាយអាស៊ី ត្រីពោ ត្រីគល់រាំង ត្រីកាហែ ត្រីខ្យា ក្រពើភ្នំ ជាដើម។ល។ ដោយសារពួកវាមិនអាចឆ្លងកាត់ទំនប់ចុះឡើង បាន។



Draft

- តំបន់គម្រោងទំហំ ៩.៣៥៥ហ.ត ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍(ប្រម៉ោយ)សរុបផ្ទៃដីមានចំនួន ៤.១៩៩,២ ហ.ត (៤៥%) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (លំអិតមើលក្នុងជំពូក៥ ចំណុច៥.១.២.៣) និងតំបន់ការពារដែនជម្រកសត្វព្រៃភ្នំសំកុសទំហំ ៤.៧៥៦,១ហ.ត(៥១%) និងឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល៣៩៩,៧ហ.ត(៤%) របស់ក្រសួងបរិស្ថាន។
- អាចនឹងប៉ះពាល់ដល់ជម្រកសត្វព្រៃ ដោយសារសកម្មភាពរបស់បុគ្គលិក-កម្មករទន្ទ្រានចូលព្រៃ ធ្វើការបរបាញ់ ឬដាក់អន្ទាក់សត្វ និងជួញដូរ ចរាចរឈើ និងសត្វព្រៃធ្វើឱ្យឈើ និងសត្វព្រៃទាំងនោះ ថយចុះឈានទៅរកការបាត់បង់ប្រភេទសត្វមួយចំនួន ។
- អាចនឹងប៉ះពាល់ដល់ទំនៀមទំលាប់ប្រពៃប្រណីរបស់ប្រជាពលរដ្ឋ ដែលរស់នៅក្បែរតំបន់ដូចជាៈ ពួកគាត់មានជំនឿលើ អារក្ស អ្នកតាព្រៃភ្នំ ដោយបង្កើតជាព្រៃអ្នកតាភ្នំជាដើម ដោយសារក្រុមហ៊ុននាំយកបុគ្គលិកកម្មករគម្រោងមកពីតំបន់ផ្សេងទៀត ឬជនបរទេស។
- អាចនឹងមានការប៉ះពាល់ដល់បរិមាណ និងគុណភាពទឹកស្ទឹងពោធិ៍សាត់នេះ ក្នុងការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋ នៅតំបន់ផ្នែកខាងក្រោម ដោយសារទឹកក្នុងអាងស្តុកមានគុណភាពមិនល្អ និងមានក្លិនស្អុយ មកពីការរលួយពីរុក្ខជាតិ ដែលលិចទឹក និងការខ្វះអុកស៊ីសែនរបស់ទឹក និងជាពិសេសអាចមានការខ្វះទឹកសម្រាប់ប្រព័ន្ធស្រោចស្រប់ ដំណាក់អំពិល និងចារឹក ។
- មានចរាចរណ៍កើនឡើង ធ្វើឱ្យមានការចង្អៀតលើដងផ្លូវ ការកកស្ទះចរាចរណ៍ ជាពិសេសអាចបង្កឱ្យមានគ្រោះថ្នាក់ចរាចរដោយសារការធ្វើដំណើររបស់អ្នកទេសចរណ៍ ប្រជាពលរដ្ឋ និងបុគ្គលិក-កម្មកររបស់គម្រោងកាន់តែកើនឡើង ដោយស្ថានភាព ផ្លូវតូចចង្អៀត និងមានចំណោទជាដើម។
- ការកើតមានការរញ្ជួយដី និងការបាក់ទំនប់ និងបាក់ភ្នំនាថ្ងៃអនាគត ដោយសារទំងន់ និងសំពាធទឹកក្នុងអាងស្តុកទឹក ដែលមានចំណុះ ៩០៣,៩លាន ម៉ែត្រគូប។
- កត្តាប្រែប្រួលអាកាសធាតុដូចជា កើនឡើងនូវកំដៅភាពរាំងស្ងួត ធ្វើឱ្យមានទឹកមិនគ្រប់គ្រាន់សម្រាប់ដំណើរការទូប៊ីនអគ្គិសនី។

**វិធានការកាត់បន្ថយ**

- នៅខាងក្រោមតំបន់ទំនប់ ដល់អាគារថាមពល តាមដងស្ទឹងមានចម្ងាយប្រមាណ៩,២គ.ម។ នៅតំបន់នេះក្រុមហ៊ុននឹងធ្វើការបញ្ចេញទឹកពីអាងចំនួន ១,៣ម$^{៣}$/វិនាទី ឥតដាច់ទាំងប្រាំង និងវស្សា។
- ត្រូវត្រៀមគ្រឿងចក្រគ្រប់គ្រាន់សម្រាប់សំអាតដីដែលបាក់ ទៅលើផ្លូវ ឬអូរដោយដឹកវាទៅទុកដាក់នៅកន្លែងមានសុវត្ថិភាព និងមានការបង្ហាប់ត្រឹមត្រូវតាមបច្ចេកទេសរបស់ការងារដី។ កន្លែងដែលបាក់នេះ ត្រូវធ្វើការដាំស្មៅ ឬដើមឈើ ឬបាញ់បាយអរ ដោយមានរន្ធបង្ហូរទឹកត្រឹមត្រូវលើជញ្ជាំងនេះត្រឹមត្រូវ។
- ពេលដែលបំពេញទឹកក្នុងអាងរួច ក្រុមហ៊ុនត្រូវធ្វើការសំអាតឈើ ដែលអណ្តែតទឹកឱ្យបានស្អាត ដោយមានកញ្ចប់ថវិកាចំនួន២០.០០០ដុល្លារអាមេរិកសម្រាប់ប្រតិបត្តិការនេះមើលតារាង៨-២ចំណុច ; លេខរៀងទី៤។
- មុនពេលបើកទឹកដំណើរការផលិតអគ្គិសនី ត្រូវផ្តល់ដំណឹងប្រាប់ឱ្យដឹងមុន ១៥ ទៅ ៣០នាទី តាមការបំពាក់ឧបករណ៍ផ្តល់សញ្ញាគ្រោះថ្នាក់ និងបន្លឺស៊ីរ៉ែនជាដើម នៅតំបន់ខាងក្រោមអាគារថាមពល ដែលមានមនុស្សរស់នៅចម្ងាយយ៉ាងតិច ៥០គ.ម តាមដងស្ទឹង ដើម្បីឱ្យអ្នករស់នៅខាងក្រោមនេះបានដឹង និងរត់គេច មកទីទួលសុវត្ថិភាព នៅពេលដែលបើកទឹកដំណើរការទួរប៊ីនម្តងៗ (ទួរប៊ីន១ បញ្ចេញទឹក ៤០ម$^{៣}$/វិន. ទួរប៊ីនពីរ ៨០ម$^{៣}$/វិន.។ ប្រសិនបើមាន ការលិចលង់តំបន់កសិកម្មរបស់ប្រជាពលរដ្ឋ ឬខូចខាតដល់ទ្រព្យសម្បត្តិ ឬដំណាំនានា ដោយសារប្រតិបត្តិគម្រោងនេះ ម្ចាស់គម្រោងជាអ្នកទទួលខុសត្រូវចេញសំណងតាមតម្លៃទីផ្សារ។ ប្រសិនបើ មន្ត្រីជំនាញរបស់ក្រសួងពាក់ព័ន្ធតម្រូវឱ្យមានវិធានការការពារកន្លែងលិច ដូចជាសាងសង់ទំនប់អមសងខាងច្រាំងស្ទឹង ម្ចាស់គម្រោង ជាអ្នកទទួលខុសត្រូវចំណាយទាំងស្រុង។

Draft

- ត្រូវសហការណ៍ជាមួយក្រសួងបរិស្ថាន និងរដ្ឋបាលជលផល មានវិធានការជារៀងរាល់ឆ្នាំរកពូជត្រីដែលងាយរងគ្រោះ ក្នុងតំបន់គម្រោង រួចយកវាទៅលែងតាមអូរ ស្ទឹង នៅក្នុងឬក្បែរតំបន់គម្រោង (មានមូលនិធិបរិស្ថាន និងសង្គម)។ (***សម្គាល់:*** ចំពោះតម្លៃនៃសំណង់សម្រាប់ ត្រីឆ្លងកាត់បានមានតម្លៃរាប់លានដុល្លារ ដែលធ្វើឱ្យតម្លៃដើមរបស់អគ្គិសនីកើនខ្ពស់ផងដែរ)។
- ធ្វើការប្រឹក្សាជាមួយរដ្ឋបាលព្រៃឈើ ដែនជម្រកសត្វព្រៃភ្នំសំកុស ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល និងអង្គការអភិរក្សនានា ដែលពាក់ព័ន្ធរកទីតាំងសមស្របក្នុងតំបន់ព្រៃក្បែរតំបន់គម្រោងនេះ សម្រាប់ដាំឈើទុកជាជម្រកដល់សត្វព្រៃផង និងដើម្បីរក្សាលំនឹងអេកូឡូស៊ីបរិស្ថានក្នុងតំបន់នេះ ជាពិសេសព្រៃឈើស្រូបទាក់ទាញទឹកភ្លៀង ដែលជាប្រភពសម្រាប់ទំនប់វារីអគ្គិសនីទៀតផង។
- សហការណ៍ជាមួយក្រសួងបរិស្ថាន និងរដ្ឋបាលព្រៃឈើ ក្នុងការការពារគម្របព្រៃឈើជុំវិញតំបន់គម្រោងជាពិសេស រក្សាព្រៃឈើសម្រាប់ស្រូបទាញទឹកភ្លៀង ជានិរន្តភាពដំណើរការគម្រោងវារីអគ្គិសនីនេះ។
- ត្រៀមមូលនិធិសមស្រប ដើម្បីការពារ និងស្តារឡើងវិញនូវជម្រកសត្វព្រៃទាំងនោះដែលបាត់បង់ (ដូចជាការដាំឈើឡើងវិញ នៅតំបន់ដែលគ្មានឈើដុះក្បែរនោះដោយធ្វើការជាមួយក្រសួងបរិស្ថាន រដ្ឋបាលព្រៃឈើ និងអង្គការអភិរក្សនានា។
- ក្រុមហ៊ុន ត្រូវធ្វើការណែនាំអប់រំដល់បុគ្គលិក-កម្មក របស់គម្រោងឱ្យមានការគោរពទំនៀមទំលាប់ប្រពៃណី និងជំនឿ របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ព្រៃភ្នំ ស្ថិតនៅជុំវិញទីតាំងគម្រោង។
- ត្រូវធ្វើការពង្រឹងកម្រាលលើកំណាត់ផ្លូវចេញចូលតំបន់គម្រោងចាប់ពីចំណុចបំបែកនៃផ្លូវជាតិ៥៥ ដល់ទីតាំងទំនប់ និងអាគារថាមពល ដែលមានប្រវែងសរុប ១២ គ.ម ព្រមទាំងមានការថែទាំផ្លូវនេះជាប្រចាំទៀតផង។
- ក្រុមហ៊ុននឹងធ្វើការផ្សព្វផ្សាយរាល់ហេតុការណ៍ដែលអាចបង្កដល់ការបាក់ទំនប់ការបាក់ភ្នំ ឬការរញ្ជួយដីក្នុងតំបន់គម្រោងដល់ប្រជាពលរដ្ឋដែលរស់ក្នុង និងក្បែរខាងគម្រោងនេះ ទាំងអស់ឱ្យបានជ្រាបហេតុការណ៍ខាងលើបានទាន់ពេលវេលាតាមតែអាចធ្វើទៅបាន បើសិនជាមានហានិភ័យបែបនេះកើតឡើង។

៧.១.៤ ដំណាក់កាលបិទគម្រោង

ក្នុងដំណាក់កាលបិទគម្រោងរបស់ក្រុមហ៊ុន KTC នៃប្រទេសកូរ៉េនេះ នឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រោយពេលដំណើរការបានតាមកិច្ចសន្យាអភិវឌ្ឍន៍គម្រោងមក ហើយចំពោះការផ្ទេរហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនីនេះនឹងមានចែងលំអិតនៅក្នុងកិច្ចសន្យា ដូចដែលរាជរដ្ឋាភិបាល បានធ្វើជាមួយក្រុមហ៊ុនវារីអគ្គិសនីផ្សេងៗទៀតដែរ។ រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបន្ទុក ធ្វើការគ្រប់គ្រងបន្ត ដូចនេះសកម្មភាពបិទគម្រោងអាស្រ័យទៅនឹងរដ្ឋាភិបាលកម្ពុជាសម្រេចខ្លួនឯង ហើយសង្ឃឹមថា ក្នុងដំណាក់កាលបិទគម្រោងរបស់ក្រុមហ៊ុនកូរ៉េ និងចិននេះ ពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ៗ ដែលគួរឱ្យកត់សម្គាល់ឡើយ។

ទន្ទឹមនិងនេះដែរ ក្រុមហ៊ុនត្រូវធ្វើផែនការច្បាស់លាស់ នៃការជួសជុលរាល់ការខូចខាតនៃសំណង់ពាក់ព័ន្ធនានារបស់គម្រោង និងត្រូវសំអាតសំណល់រឹង-រាវ គ្រប់ប្រភេទចេញពីការដ្ឋាន កន្លែងស្នាក់នៅរបស់បុគ្គលិក-កម្មករគម្រោង រោងជាង ចំណតយានយន្ត ឃ្លាំង ផ្ទះបាយជាដើម ដោយសំណល់ទាំងនោះត្រូវធ្វើកន្លែងទុកដាក់ឱ្យមានសុវត្ថិភាពបរិស្ថានល្អ។

៧.២ ហេតុប៉ះពាល់បរិស្ថានវិជ្ជមានសំខាន់ៗ

**ធនធានរូបសាស្ត្រ និងបរិស្ថាន**

ក.ជលសាស្ត្រ

ការប្រលែងបញ្ចេញទឹកពីទំនប់មេមកខាងក្រោមជាមធ្យម១.៣ម$^{៣}$/វិនាទី នៅរដូវប្រាំងធ្វើឱ្យកំណាត់ស្ទឹងពោធិ៍សាត់ពីទំនប់មកដល់អាគារថាមពលមានទឹកគ្រប់គ្រាន់សម្រាប់រក្សាជីវៈចម្រុះរបស់កំណាត់នៃស្ទឹងនេះ។នារដូវប្រាំងធ្វើឱ្យ ប្រព័ន្ធធារាសាស្ត្រដំណាក់អំពិល និងចារីកទទួលបានទឹកបន្ថែមទៀតពីការបង្ហូរទឹកចេញតាមទួរប៊ីន យ៉ាងហោចណាស់ចំនួន១ ដែលមានជារទឹកប្រមាណ ៤០ម$^{៣}$/វិនាទី (បើដំណើរការទាំង២ទួប៊ីននោះមាន ៨០ម$^{៣}$/វិនាទី)។

ខ. មច្ឆជាតិ

បរិមាណដ៏ធំធេងនៃអាងទឹកនេះ អាចបង្កលក្ខខណ្ឌសមស្របសម្រាប់ការអភិរក្ស រួមទាំងការអនុវត្តកិច្ចការពារបរិស្ថាន ដូចដែលបានចែងក្នុងរបាយការណ៍នេះ និងធ្វើឱ្យការកើនឡើងនៃប្រភេទត្រី និងវារីសត្វ មួយចំនួនធំក្នុងតំបន់ស្ទឹង និងអាងនេះផងដែរ។

**ធនធានសេដ្ឋកិច្ច និងសង្គម**

ក. ថាមពលអគ្គិសនី

គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់នេះ មានអនុភាពសរុប ៨០មេហ្គាវ៉ាត់ (MW) ហើយការផលិតថាមពលជាមធ្យម ក្នុង១ឆ្នាំ អាចស្មើនឹង ៣៦៧,១២ ជីហ្គាវ៉ាត់ម៉ោង (GWh) គឺប្រមាណជា៣៧% នៃថាមពលអគ្គិសនីដែលប្រទេសកម្ពុជាផលិតបាន សរុបនៅឆ្នាំ ២០១០ (៩៦៨,៣៦ លានគីឡូវ៉ាត់ម៉ោង(kWh)មិនរាប់បញ្ចូលថាមពលនាំចូលពីប្រទេសជិតខាង គឺប្រទេសថៃ និងវៀតណាមទេ)។

ខ. ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

គម្រោងនេះបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងតំបន់នេះ ដូចជានឹងត្រូវសាងសង់ផ្លូវចូលទៅគម្រោងវារីអគ្គិសនីនេះមានប្រវែងសរុបប្រមាណ៣០គ.មក្នុងនោះក្រុមហ៊ុន នឹងធ្វើសាងសង់ស្ពានកាត់ស្ទឹងពោធិ៍សាត់១ ផងដែរ។

គ. ការប្រើប្រាស់ដី/តម្លៃដី និងទេសចរណ៍

ដោយសារឥទ្ធិពលនៃការអភិវឌ្ឍគម្រោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វា អាចនឹងធ្វើឱ្យមានការកែប្រែតំបន់នេះឱ្យទៅជាតំបន់ទេសចរណ៍ធម្មជាតិ នៅក្នុងតំបន់គម្រោង ដែលកំពុងពេញនិយមលើពិភពលោក ដែលបច្ចុប្បន្ននេះ(២០១៧) មិនទាន់មានការអភិវឌ្ឍនៅឡើយ។

ឃ. ផ្តល់ការងារ និងលើស្ទួយជីវភាព

គម្រោងផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក្នុងពេលសាងសង់គម្រោងនេះ គ្រោងជ្រើសបុគ្គលិក-កម្មករជាមធ្យមចំនួនប្រហែលជា ៣០០នាក់។

ង. ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់នេះ នឹងផ្តល់ស្ថេរភាពក្នុងការផ្គត់ផ្គង់ចរន្តអគ្គិសនីដល់ការអភិវឌ្ឍលើគ្រប់វិស័យរាប់តាំងពីការប្រើប្រាស់សម្រាប់បំភ្លឺតាមលំនៅដ្ឋាន ទីក្រុង ការបំរើឱ្យវិស័យកសិកម្ម វិស័យទេសចរណ៍ ជាពិសេសវិស័យសិប្បកម្ម និងឧស្សាហកម្ម ដែលជាគ្រឹះដ៏រឹងមាំក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ជាពិសេសធ្វើឱ្យធានាបាននូវតម្លៃភ្លើងថោក មានស្ថេរភាពក្នុងការប្រើប្រាស់ និងឯករាជ្យក្នុងការផ្គត់ផ្គង់អគ្គិសនីរបស់កម្ពុជាទៀតផង។

### ៧.៣ ហេតុប៉ះពាល់បរិស្ថានសំខាន់ៗ និងវិធានការកាត់បន្ថយនៃប្រព័ន្ធខ្សែបញ្ជូនចរន្តតង់ស្យុងខ្ពស់ ២៣០ គ.វ៉

៧.៣.១ ដំណាក់កាលមុនសាងសង់គម្រោង (រចនាគម្រោង)

**ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន**

- អាចរំខានដល់ជម្រកសត្វព្រៃនៅក្នុង និងក្បែរខាងតំបន់គម្រោង ដោយសារការត្រួសត្រាយព្រៃ និងសំឡេងអ៊ូអររបស់ បុគ្គលិក-កម្មករក្នុងការធ្វើដំណើរសិក្សា នៅទីតាំងមួយចំនួនតាមគន្លងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០គ.វ៉ គឺពីអាគារថាមពលឆ្ពោះទៅបង្គោលរបស់បណ្តាញខ្សែ ២៣០គ.វ៉ អូរសោម-ពោធិ៍សាត់។
- ប៉ះពាល់ដល់សុខភាពអ្នកសិក្សាគម្រោង ដោយសារតំបន់នេះគ្មានផ្សារសម្រាប់លក់ទឹកសម្រាប់ផឹក ហើយក៏ជាតំបន់ព្រៃភ្នំ មានភូមិប្រជាជនតិចតួចប៉ុណ្ណោះដែរ។
- ការប៉ះពាល់ដល់ព្រៃឈើដោយសារការធ្វើផ្លូវ និងគន្លងខ្សែភ្លើងច្រើនសាំញ៉ាំ ដែលបង្កឱកាសឱ្យជនខិលខូចកាប់ឈើ និង ដឹកជញ្ជូនឈើបានដោយងាយស្រួល។

Draft

- អាចបង្កឱ្យមានការប៉ះពាល់ដល់សុខុមាលភាពបុគ្គលិក-កម្មកររបស់ក្រុមហ៊ុន ដោយសារតំបន់គម្រោង ជាតំបន់កើតជំងឺគ្រុនចាញ់ គ្រុនសន្និ។ល។ តំបន់ខ្លះនៃតំបន់គម្រោងមានគ្រាប់មីន និងមានដាក់អន្ទាក់សត្វហើយមានពពួកសត្វសាហាវ និងអសិរពិស ជាពិសេសដោយសារជនប្រដាប់អាវុធអនាធិបតេយ្យ ដើរបរបាញ់សត្វ កាប់ឈើខុសច្បាប់ ដែលអាចធ្វើឱ្យក្រុមសិក្សាគម្រោងមានគ្រោះថ្នាក់ដល់ជីវិតផងដែរ។
- អាចមិនបានគិតអំពីកត្តាប្រែប្រួលអាកាសធាតុ ដូចជាការកើនឡើងនូវកំដៅ កម្រិត ព្យុះជាដើម អាចធ្វើឱ្យគុណភាពសំណង់នៃប្រព័ន្ធខ្សែបញ្ជូនអគ្គិសនីមិនរឹងមាំតាមការគ្រោងទុក។

**វិធានការកាត់បន្ថយ**

- កំណត់ពេលវេលាធ្វើការតែពេលថ្ងៃ ដើម្បីមិនឱ្យមានការរំខានដល់សត្វព្រៃឡើយ។
- ធ្វើការផ្គត់ផ្គង់ទឹកផឹកឱ្យបានទាន់ពេលវេលាដល់ក្រុមសិក្សា និងពន្យល់អប់រំអ្នកទាំងនោះមិនឱ្យផឹកទឹកឆៅបើការផ្គត់ផ្គង់ទឹកស្អាតមិនទាន់ ពោលគឺទឹកដែលដងពីរអូរ ឬស្ទឹងក្នុងតំបន់ត្រូវដាំពុះជាមុនសិនទើបផឹកបាន។
- ធ្វើការទំនាក់ទំនងជាមួយមន្ទីររ៉ែ និងថាមពលខេត្តពោធិ៍សាត់ និងមន្ទីរពាក់ព័ន្ធ ដើម្បីរកមធ្យោបាយចូលទៅទីតាំងគម្រោង ដោយសុវត្ថិភាពក្នុងការសិក្សានេះ។
- ក្រុមហ៊ុនធ្វើការទាក់ទងយ៉ាងជិតស្និតជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រជាពលរដ្ឋមូលដ្ឋាននិងអង្គភាពបោសសំអាតមីន ដើម្បីធ្វើការបង្ហាញតំបន់មានគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះទាំងឡាយ ដែលបន្សល់ទុកពីសម័យសង្គ្រាម។
- ការរចនាគម្រោងវាសំខាន់ណាស់សម្រាប់ដំណាក់កាលគម្រោងក្រោយៗទៀត ដូចនេះក្នុងដំណាក់កាលនេះនឹងធ្វើការគ្រោងរចនានូវហេដ្ឋារចនាសម្ព័ន្ធខ្សែបញ្ជូនចរន្តនេះមានដូចតទៅៈ
- គន្លងខ្សែគឺ ១៥ម សងខាងពីអ័ក្សបង្គោលហ្វែមដែក (សរុប ៣០ម)
- ទំហំផ្ទៃដីសម្រាប់ធ្វើគ្រឹះបង្គោលអគ្គិសនីគឺ ១៥ម x ១៥ម
- ចំនួនបង្គោលអគ្គិសនីគឺ ១៣បង្គោលហ្វែមដែក ហើយចម្ងាយប្រឡោះពីបង្គោលមួយទៅបង្គោលមួយទៀត គឺ ៣៥០ទៅ៤៥០ម។ កំពស់របស់បង្គោលគឺ ចាប់ពី ២០ម ទៅ ៤០ម ប្រែប្រួលទៅតាមសណ្ឋានដី។
- សម្ភារសំណង់មានគុណភាពតាមស្តង់ដារអន្តរជាតិធន់នឹងការប្រែប្រួលអាកាសធាតុ និងធានាដល់ការប្រើប្រាស់ប្រព័ន្ធខ្សែបញ្ជូនអគ្គិសនីនេះ តាមការគ្រោងទុកតាមកិច្ចសន្យា របស់ក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាលកម្ពុជា។

៧.៣.២ ដំណាក់កាលសាងសង់គម្រោង

**<u>ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន</u>**

- បណ្តាលឱ្យមានការប្រែប្រួលសណ្ឋានដី និងឋានលេខា ជាមធ្យមក្នុងទីតាំងគម្រោង ដោយសារសកម្មភាពឈូសឆាយធ្វើផ្លូវចូល និងពង្រាបដីស្រទាប់លើ ការជីកយកដី និងថ្ម ដើម្បីធ្វើការសាងសាង់ប្រព័ន្ធខ្សែបញ្ជូនអគ្គិសនី ដូចជា សាងសង់បង្គោលអគ្គិសនី និងការដំឡើងខ្សែជាដើម។
- ប៉ះពាល់ដល់គុណភាពទឹក ដោយសារសកម្មភាពសាងសង់ដែលបណ្តាលមកពីការហូរច្រោះ ដីស្អុយតាមបង្គោលអគ្គិសនីតាមផ្លូវចូលទៅសាងសង់បង្គោលហូរចូលទៅក្នុងប្រឡាយ-អូរ-ស្ទឹង ដែលស្ថិតក្បែរកន្លែងសាងសង់នោះ។
- បង្កឱ្យមានការហូរច្រោះដី ដោយសារការឈូសឆាយដីស្រទាប់លើ ដើម្បីសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់គម្រោង (ផ្លូវចូល បង្គោលអគ្គិសនី និងដំឡើងខ្សែភ្លើង)ដោយសារការធ្វេសប្រហែសមិនគោរពតាមបទដ្ឋានការងារដី ដែលធ្វើឱ្យមានការហូរច្រោះដី ពិសេសនៅរដូវវស្សា។
- ក្នុងដំណាក់កាលសាងសង់នេះមានការបំពុលគុណភាពទឹកប្រឡាយ-អូរ-ស្ទឹង ដោយសារការសាងសង់បង្គោលអគ្គិសនី និងការងារសាងសង់ដទៃទៀត បណ្តាលមកពីការខួង ឬការងារដី ការងារបេតុង និងការងារគ្រឹះ ដែលការដ្ឋានសាងសង់នេះស្ថិតនៅជិតប្រភពទឹកទាំងនេះ។

Draft

- មានការបំពុលខ្យល់ដោយសារការដុតព្រៃឈើ ដើមឈើ កំទេចឈើ ដើម្បីសំអាតការដ្ឋាន និងនៅតាមគន្លងខ្សែ ហើយ ផ្សែងដែលបំភាយចេញពីគ្រឿងចក្រសាងសង់ និងរថយន្តដឹកជញ្ជូនសម្ភារសម្រាប់ការងារសាងសង់ និងការហុយធូលីដីពីមធ្យោបាយដឹកជញ្ជូនទាំងនេះរបស់គម្រោង។
- បង្កឱ្យប៉ះពាល់ដល់គុណភាពដីស្រទាប់លើ នៅជុំវិញទីតាំងបង្គោលភ្លើងដោយសារចោលដីស្អុយ (ដីដែលជីកពីស្រទាប់ ក្រោមគ្មានជីជាតិ) នៅជុំវិញទីតាំងនោះ។
- មានការប៉ះពាល់ដល់តំរពារសង្កាត់រដ្ឋបាលព្រៃឈើប្រមោយ ដែលមានគម្របព្រៃឈើចំនួន១៣,៦ គឺជាព្រៃស្រោង ហើយព្រៃនេះក៏មានសត្វព្រៃ ជាច្រើនទៀតរស់នៅផងដែរ។
- មានការប៉ះពាល់ដល់ផ្ទៃដីព្រៃឈើសរុប១៣,៦ហ.ត ដោយសារការសាងសង់បង្គោលអគ្គិសនីខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០គ.វ៉ ពីអាគារថាមពលមកខ្សែរបស់ក្រុមហ៊ុន Cambodia Power grid (CPG) ប្រវែង៥គ.ម។

**វិធានការកាត់បន្ថយ**

- ធ្វើការសាងសង់ជាទ្រង់ទ្រាយធំតែរដូវប្រាំង ដើម្បីទប់ស្កាត់ការហូរច្រោះ ដែលនាំឱ្យខូចសណ្ឋានដីនៅរដូវវស្សា។
- ធ្វើការកាត់បន្ថយការធ្វើឱ្យល្អក់ខ្លាំងដោយយកដីស្អុយដែលនៅក្បែរប្រភពទឹកចេញ និងកិនបង្ហាប់ដី ដាំស្មៅ នៅកន្លែង ដែលបានសាងសង់បង្គោលរួចហើយ ឱ្យបានមុនពេលរដូវភ្លៀងធ្លាក់។
- ធ្វើការបង្ហាប់ដីក្នុងតំបន់សាងសង់ឱ្យបានត្រឹមត្រូវតាមបទដ្ឋានការងារបច្ចេកទេស។
- ការឈូសឆាយទ្រង់ទ្រាយធំក្រុមហ៊ុនមិនធ្វើនៅរដូវវស្សាទេ។
- មិនដុតព្រៃឈើក្នុងតំបន់ដែលត្រូវសំអាតតាមគន្លងខ្សែ៣០ម.នេះទេ គឺក្រុមហ៊ុនធ្វើការសហការណ៍ជាមួយរដ្ឋបាលព្រៃឈើ ដើម្បីត្រួតពិនិត្យទំហំដើមឈើសម្រាប់ដេញថ្លៃ និងឈើមួយចំនួនអាចយកមកកែច្នៃសម្រាប់ប្រើប្រាស់។
- ពង្រាបដី ឬថ្មដែលចាក់ចោល ដោយយកដីមានជីជាតិលប់ពីលើ រួចដាំស្មៅឡើងវិញក្នុងតំបន់សាងសង់បង្គោលអគ្គិសនីនេះ (១៥ x ១៥ម)។ ត្រូវធ្វើជញ្ជាំងផ្លូវឱ្យមានជើងទេរត្រឹមត្រូវជៀសវាងការបាក់ដីនៅពេលមានភ្លៀងធ្លាក់ ពីព្រោះតំបន់នេះ មានភ្លៀងច្រើន។
- សូមធានាមិនកាប់ព្រៃឈើនៅក្រៅពីទីតាំងសាងសង់បង្គោលអគ្គិសនី និងតាមចំណីខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គ.វ៉ ដូចដែលមានបង្ហាញនៅក្នុងប្លង់រចនាគម្រោងលំអិតឡើយ។

៧.៣.៣ ដំណាក់កាលប្រតិបត្តិ និងថែទាំគម្រោង

**<u>ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន</u>**

- អាចមានការហូរច្រោះ នាំឱ្យខូចគុណភាពដី នៅតាមទីជំរាលជើងទេរ នៃជញ្ជាំងភ្នំ ឬដីទួលតាមដងផ្លូវចូលសាងសង់បង្គោលអគ្គិសនី ហើយផ្លូវនេះប្រើប្រាស់សម្រាប់ការថែទាំគម្រោង។ ការបាក់ដីនៅតាមកន្លែងទាំងនេះដោយសារទឹកភ្លៀងខ្លាំងធ្វើឱ្យស្ទះផ្លូវ ឬបាត់បង់ជីជាតិដីនៅតំបន់នេះដោយសារដីនេះគ្របពីលើ។
- អាចនឹងប៉ះពាល់គុណភាពទឹកលើដី និងក្រោមដី ដោយសារការប្រើប្រាស់សារធាតុគីមី ដើម្បីបង្អាក់ការលូតលាស់របស់ដើមឈើក្នុងពេលដំណើរការគម្រោងនេះ។
- អាចប៉ះពាល់ដល់តំបន់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍(នៅតំបន់ប្រមោយ) ដោយសារមានការទន្ទ្រានរានព្រៃយកដីធ្វើកម្មសិទ្ធិខុសច្បាប់ ព្រោះមានផ្លូវចេញចូលក្នុងតំបន់ស្រួល ពីសម្នាក់ជនឆ្លៀតឱកាសមួយចំនួន។
- អាចនឹងប៉ះពាល់ដល់ធនធានព្រៃឈើ ដែលជាជម្រកសត្វព្រៃច្រើនប្រភេទដូចមានចែងក្នុងជំពូក៥ ចំណុច ៥.១.២.១ ដោយសកម្មភាពកាប់សំអាតមែក ឬដើមឈើតាមគន្លងខ្សែបញ្ជូនអគ្គិសនីនេះ ដោយមិនឱ្យខ្ពស់ជាង ៣ម។
- អាចមានការឆក់ដល់មនុស្ស-សត្វ ជាពិសេសពពួកសត្វស្វា និងទោច ដោយសារសត្វនេះចូលចិត្តឡើងបង្គោលអគ្គិសនី។
- អាចមានការទន្ទ្រានកាន់កាប់ដីពីអ្នកមកពីខាងក្រៅ និងជនឱកាសនិយមប្រើមធ្យោបាយគ្រប់រូបភាព ដើម្បីចាប់យកដី ក្នុងតំបន់ព្រៃការពារនេះ គួរឱ្យព្រួយបារម្ភពីព្រោះគម្រោងមានផ្លូវចេញចូលស្រួល បច្ចុប្បន្នគ្មានផ្ទះប្រជាជន



Draft

រស់នៅក្រោមគន្លង នៃខ្សែនេះទេ (ខ្សែ២៣០គ.វ៉ មិនទាន់បានសាងសង់នៅឡើយ ការសិក្សាយកតាមចំណុចយាមកា ដែលចែងក្នុងជំពូក៤ ចំណុច៤.៣) ដូចបានរៀបរាប់ខាងលើរួចមកហើយ។ ហេតុដូច្នេះហើយក្រោយពីការសង់គម្រោងនេះរួចនឹងមាន ការសង់លំនៅដ្ឋាន និងសំណង់ផ្សេងៗទៀតនៅក្រោមគន្លងនេះមិនខានឡើយ ដែលធ្វើឱ្យក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋានពិបាកដោះស្រាយ ពីព្រោះកំពស់ខ្ទមផ្ទាល់ដី យ៉ាងហោចណាស់ក៏សរសរដំបូលមានកំពស់ពី ៣,៥ម ទៅ ៤ម ដែរលើសពីនេះអ្នក ស្រុកទាំងនេះមានដំឡើងអង់តែន ឬលើកបង្គោលផ្សេងៗ ដែលមានកំពស់ខ្ពស់ជា៣ម ដែលនឹងធ្វើឱ្យប៉ះពាល់ដល់វត្តិភាពរបស់ពួកគេ។

- អាចនឹងមានការប៉ះពាល់ដល់ត់បំន់នេះដែលជាតំបន់ទេសចរណ៍-បរិស្ថាន ឬទេសចរណ៍ធម្មជាតិ ដោយសារការប្រមូល សំណល់រឹង-រាវគ្រប់ប្រភេទ ដូចជា សំបកកង់ឡាន ស្បោងប្លាស្ទិក ក្រណាត់ សំបកដប គ្រប់ប្រភេទមិនបានស្អាតតាម ការដ្ឋានសាសង់បង្គោល នៅតាមទីតាំងបោះជំរុំស្នាក់នៅបណ្តោះអាសន្ន កន្លែងបង្គន់ បន្ទប់ទឹក ផ្ទះបាយ ឃ្លាំងស្តុកសម្ភារ រោងជាងជាដើម ដែលធ្វើឱ្យកខ្វក់តំបន់នេះ។
- អាចមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស នៅធ្វើដំណើរកាត់តាមគន្លងខ្សែបញ្ជូនចរន្ត២៣០kV នេះ ដោយសារការរងឥទ្ធិពលដែនអគ្គិសនីភ្លុចអាំងឌុចស្យុងអេឡិកត្រូស្តាទិក និងអេឡិកត្រូម៉ាញេទិកនៅតាមគន្លងខ្សែ៥គ.ម ឬឆ្លងចរន្តតាមដើមឈើដែលមានមែកវាទោទៅប៉ះចូលក្នុងដែនអគ្គិសនីទាំងនេះ។
- ការឆេះព្រៃក្នុងតំបន់គម្រោងដែលបណ្តាលមកពីការធ្វេសប្រហែសបច្ចេកទេស ឬទុស្សេខ្សែភ្លើង ឬអំពើភេរវកម្មក៏អាចបង្កឱ្យមានមហន្តរាយ/គ្រោះថ្នាក់ធំដល់ប្រព័ន្ធខ្សែបញ្ជូនអគ្គិសនីសំខាន់ៗ របស់គម្រោងធនធានធម្មជាតិក្នុងតំបន់ និងអាយុជីវិតមនុស្សទៀតផង។

**<u>វិធានការកាត់បន្ថយ</u>**

- ត្រូវមានអ្នកត្រួតពិនិត្យជាប្រចាំ នៅតាមផ្លូវចូលទៅបង្គោលអគ្គិសនី ជាពិសេសនៅតាមជញ្ជាំងភ្នំខ្ពស់ៗ ប្រសិនបើមានការបាក់ត្រូវកាយដីនោះចេញ ជាបន្ទាន់រួចយកទៅចាក់នៅកន្លែងមានសុវត្ថិភាព មិនប៉ះពាល់ដល់បរិស្ថានហើយ ត្រូវដាំស្មៅនៅកន្លែងបាក់នេះឡើងវិញ ដើម្បីការពារការហូរច្រោះទៀត។
- មិនត្រូវប្រើប្រាស់សារធាតុគីមីដើម្បីសំអាត ឬបង្អាក់ការលូតសាស់របស់ដើមឈើនោះទេ។
- ធ្វើការសហការណ៍ជាមួយអាជ្ញាធរ និងរដ្ឋបាលព្រៃឈើថែទាំស្លាកប៉ាន់ណូដែលបានដំឡើងនេះជាប្រចាំ ដើម្បីឱ្យជនឱកាសនិយមទាំងនោះបានឃើញ បើល្មើសនឹងត្រូវជាប់គុករហូតដល់១០ឆ្នាំ។ ជាងនេះទៅទៀត នៅតាមបង្គោលអគ្គិសនី ២៣០គ.វ៉ និមួយៗក៏ត្រូវដាក់ស្លាកនេះដែរ។ ក្រុមហ៊ុនមានកញ្ចប់ថវិកាចំនួន ២៥.០០០ ដុល្លារអាមេរិក សម្រាប់ការអប់រំ ផ្សព្វផ្សាយបរិស្ថាន (មើលក្នុងតារាង ៨-២ចំណុច vi)។
- ការកាប់សំអាតមែក ឬដើមឈើនេះ គឺក្រុមហ៊ុននឹងកាប់តែក្នុងទំហំនៃចំណីគន្លងខ្សែបញ្ជូនអគ្គិសនី (ម្ខាង១៥មសរុប៣០ម) តែប៉ុណ្ណោះហើយនឹងសហការណ៍ថែរក្សាព្រៃឈើសងខាងចំណីគន្លងខ្សែបញ្ជូនអគ្គិសនីនេះ ជាមួយមន្ត្រីជំនាញព្រៃឈើឱ្យបានល្អប្រសើរ។
- ក្រុមហ៊ុនត្រូវសង់គ្រឿងការពារមនុស្ស-សត្វទៅនឹងបង្គោលទាំងបួន ដើម្បីការពារកុំឱ្យមនុស្ស-សត្វឡើងបាន។
- ក្រុមហ៊ុនត្រូវដាក់ស្លាកតំបន់ដីចំណីគន្លងខ្សែ២៣០គ.វ៉នេះ នៅតាមបង្គោលអគ្គិសនីនៅចន្លោះរៀងរាល់ ២បង្គោលម្តង នៃខ្សែ២៣០គ.វ៉នេះ ដើម្បីឱ្យប្រជាជនបានដឹង និងឃើញ ដូចក្រសួងសាធារណការ ដែលបានដាក់តាមផ្លូវជាតិនានា។
- ក្រុមហ៊ុនត្រូវធ្វើការប្រមូលសំរាម សំណល់រឹង-រាវ ទាំងអស់នោះឱ្យបានស្អាតពីទីតាំងដូចបានរៀបរាប់ខាងលើរួចសំណល់នេះត្រូវដឹកយកទៅដាក់ក្នុងរណ្តៅសុវត្ថិភាព (ឆ្ងាយពីប្រភពទឹក) រួចកប់វាឱ្យបានត្រឹមត្រូវ។ ចំណែកឯការដ្ឋាន ឬទីតាំងបោះជំរុំស្នាក់នៅបណ្តោះអាសន្ន និងទីតាំងផ្សេងៗទៀត របស់អ្នកម៉ៅការ ក្រុមហ៊ុនក៏ត្រូវទទួលខុសត្រូវក្នុងការសំអាតផងដែរ។
- ក្រុមហ៊ុនត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីគ្រោះថ្នាក់ ដែលបណ្តាលមកពីការរស់នៅក្រោម ឬលើកបង្គោលលោហៈ ក្នុងចំណីខ្សែបញ្ជូនអគ្គិសនី ឬឡើងបង្គោលអគ្គិសនី និងហាមឃាត់ដាច់ខាតនូវទង្វើខាងលើ។

- ក្រុមហ៊ុនត្រូវបំពាក់ប្រព័ន្ធផ្តាច់ភ្លើងដោយស្វ័យប្រវត្តិ ដើម្បីផ្តាច់ចរន្តអគ្គិសនីឱ្យទាន់ពេលវេលា ការពារអាយុជីវិតមនុស្ស-សត្វ នៅពេលមានបញ្ហាគ្រោះថ្នាក់ពីអគ្គិសនីនេះ។

៧.៣.៤ ដំណាក់កាលបិទគម្រោង

ក្នុងដំណាក់កាលបិទគម្រោងរបស់ក្រុមហ៊ុន KTC របស់ប្រទេសកូរ៉េ និងចិន នឹងធ្វើឡើងក្រោយពីចប់កិច្ចសន្យាជាមួយរាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា នឹងទទួលបន្ទុកធ្វើការគ្រប់គ្រងបន្ត សង្ឃឹមថាក្នុងដំណាក់កាលបិទគម្រោងរបស់ក្រុមហ៊ុនកូរ៉េ និងចិននេះ ពុំមានការប៉ះពាល់បរិស្ថានអវិជ្ជមានសំខាន់ដែល គួរឱ្យកត់សម្គាល់ឡើយ។

ក្រុមហ៊ុនត្រូវធ្វើការសំអាតសំណល់រឹង-រាវ គ្រប់ប្រភេទចេញពីទីតាំង សំណង់ហេដ្ឋារចនាសម្ព័ន្ធគម្រោងវារីអគ្គិសនីនេះ ទាំងអស់កន្លែងការិយាល័យ កន្លែងស្នាក់នៅ ឃ្លាំង រោងជាង ចំណតរថយន្ត ជាពិសេសនៅកន្លែងចាក់សំរាមនិងកន្លែងបង្ហូរទឹកស្អុយ។

## ៨. ផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងតំបន់គម្រោង

នៅក្នុងជំពូកនេះ គឺរៀបរាប់អំពីផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប) ដែលនឹងត្រូវអនុវត្តន៍តាមដំណាក់កាលរបស់គម្រោង ជាពិសេសក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិថែទាំគម្រោង និងបញ្ចប់គម្រោង។ គោលបំណងសំខាន់ នៃផ.គ.ប នេះគឺត្រួតពិនិត្យ តាមដាននូវការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលបានចែងក្នុងជំពូកទី៧ និង៨។

យោងតាមអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងយោងតាមលទ្ធផលនៃការសិក្សា ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គម ដែលបង្កឡើងដោយសារសកម្មភាពនៅគ្រប់ដំណាក់កាលរបស់គម្រោងដូចបានរៀបរាប់នៅក្នុងជំពូកទី៧ និងជំពូកទី៨ ដែលម្ចាស់គម្រោងនឹងរៀបចំកំណត់នូវវិធានការសំខាន់ៗមួយចំនួនសម្រាប់ធ្វើការទប់ស្កាត់ និងកាត់បន្ថយនូវរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដើម្បីធានាបានការគ្រប់គ្រងធនធានបរិស្ថានតំបន់នោះ ដោយប្រសិទ្ធិភាព ស្របទៅតាមលក្ខណៈបច្ចេកទេស និងបទដ្ឋានបរិស្ថានព្រមទាំងធានាឱ្យគម្រោងអភិវឌ្ឍន៍ប្រកបដោយស្ថេរភាព ដែលក្នុងនោះ រួមមាន(ចំណុចសំខាន់ៗដែលត្រូវសរសេររបាយការណ៍ជូនក្រសួងបរិស្ថាន):

- ការរៀបចំផ្នែក ឬក្រុមទទួលខុសត្រូវសម្រាប់ការអនុវត្តផែនការការងារ។
- ការកំណត់ពេលវេលាធ្វើការងារឱ្យច្បាស់លាស់ ក្នុងកិច្ចការការពារបរិស្ថាន។
- ការបំពាក់ឧបករណ៍ការពារសុខភាព គ្រោះថ្នាក់ និងគ្រឿងចក្រទំនើបៗតាមបែបផែនបច្ចេកទេស។
- កិច្ចការពារ និងបង្ការជំងឺរាតត្បាតផ្សេងៗ។
- ការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់សារធាតុពុល។
- ការធ្វើកន្លែងទុកសំណល់រឹង។
- ការការពារការហូរច្រោះនៅកន្លែងកាយជញ្ជាំងភ្នំនិងកន្លែងចាក់សំណល់ដីនិងថ្មដោយដាំស្មៅនិងដើមឈើការពារ។
- ការកាត់បន្ថយភាពល្អក់នៅកន្លែងលាងថ្ម កន្លែងយកថ្ម និងកន្លែងរោងចក្រលាយបេតុង។
- កិច្ចការជំរុញឱ្យមានការដាំដើមឈើ នៅទីសាធារណៈ ឬតំបន់ជុំវិញតំបន់ការពារទាំងនោះ។
- ការធ្វើកិច្ចសហប្រតិបត្តិការណ៍ជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យមើលទីតាំងបច្ចេកទេស និងទទួលយកនូវការកែប្រែបច្ចេកទេសណាមួយដែលជំនាញតម្រូវឱ្យធ្វើ។
- ការធ្វើការអភិរក្ស ប្រភេទសត្វព្រៃសំខាន់ៗដែលធ្លាប់មាននៅតំបន់គម្រោង និងការព្រលែងកូនត្រីមេពូជ។
- ការធ្វើការផ្សព្វផ្សាយ និងអប់រំណែនាំអំពីប្រភេទព្រៃឈើ និងពពួកសត្វព្រៃ ដែលត្រូវអភិរក្សក្នុងតំបន់គម្រោង។
- ការធ្វើការផ្សព្វផ្សាយ និងអប់រំណែនាំ វិធីសាស្ត្រការពារសុខភាពអនាម័យ-សុវត្ថិភាពការងារ។
- ការធ្វើការផ្សព្វផ្សាយមិនឱ្យប្រព្រឹត្តបទល្មើសព្រៃឈើ និងសត្វព្រៃការទន្ទ្រានកាន់កាប់ដីព្រៃឈើការពារ និងតាមគន្លងខ្សែ ២៣០គ.វ៉ ដូចជាការដំឡើងប៉ាណូធំៗ ការដាក់ស្លាកសេចក្តីជូនដំណឹងអំពីចំណើគន្លងខ្សែ និងស្លាកសញ្ញាគ្រោះថ្នាក់ ដោយសារតង់ស្យុងខ្ពស់ជាដើម។
- ការត្រៀមថវិកាបំរុងទុកសម្រាប់ប្រតិបត្តិផែនការគ្រប់គ្រងបរិស្ថាន និងការចំណាយលើថវិកានេះ។



Draft

- ការការពារបរិស្ថានក្នុងតំបន់គម្រោង និងជុំវិញតំបន់គម្រោង គឺមានសារៈសំខាន់ណាស់ ដើម្បីធានាឱ្យដំណើរការគម្រោងមានចីរភាព។ ផ្អែកតាមផែនការនៃការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុន និងផែនការត្រួតពិនិត្យ អង្កេតបរិស្ថានរបស់គណៈកម្មការចំរុះរបស់រាជរដ្ឋាភិបាលកម្ពុជានោះ។

## ៩. ការវិភាគសេដ្ឋកិច្ច និងតម្លៃបរិស្ថាន

ការវាយតម្លៃបរិស្ថាន និងសង្គមលើគម្រោងវិនិយោគសម្រាប់អភិវឌ្ឍន៍វារីអគ្គិសនីស្ទឹងពោធិ៍សាត់១ ខេត្តពោធិ៍សាត់នេះ ដែលក្រុមហ៊ុន KTC បានឱ្យ SAWAC Consultants for Development ធ្វើការសិក្សាស្រាវជ្រាវនោះ រួមមានតម្លៃបរិស្ថាន រូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងបរិស្ថានសង្គម ដើម្បីរកឱ្យឃើញថាគម្រោង ត្រូវបំពេញបន្ថែមនូវតម្លៃបរិស្ថានលើការវិនិយោគនេះ។

គម្រោងស្តារបរិស្ថានរបស់គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ មានសរុបចំនួន ៨.៦៨៩.៣៧៦ ដុល្លារអាមេរិកសម្រាប់ដំណាក់កាលសាងសង់រយៈពេល ៤ឆ្នាំ និងសម្រាប់ដំណាក់កាលក្រោយសាងសង់គម្រោង។

នៅក្នុងកញ្ចប់ថវិកានេះ មានថវិកាសម្រាប់មូលនិធិបរិស្ថាន និងសង្គម សម្រាប់មួយជីវិតគម្រោង (រយៈពេល ៣៥ឆ្នាំ) សរុប ៨២៦,៤៨០ ដុល្លារអាមេរិក (ចូលរួមដាំដើមឈើ និងបង្កើតសហគមន៍ការពារអភិរក្សព្រៃឈើ, ការឧបត្ថម្ភអ្នកល្បាត ការពារព្រៃឈើ និងសត្វព្រៃ (១០នាក់), និងចូលរួមអភិរក្សជលផល (ក្រពើភ្នំ/ក្រពើត្រី) និងការព្រលែងកូនត្រី)។

យោងតាមការវិភាគក្នុងតារាង៩-១បញ្ជាក់ថា ការបាត់បង់ព្រៃឈើក្នុងតំបន់គម្រោងធំ ហើយរហូតដល់ពេល ៨ ឆ្នាំទើបអាចស្តារបរិស្ថានព្រៃឈើ និងត្រី បានឡើងវិញគិតរាប់ចាប់ពីដំណាក់កាលប្រតិបត្តិថៃទាំគម្រោងទៅ (ឃើញតម្លៃចំណេញចំនួន ៧២៧.៩៤៥ដុល្លារ នៅឆ្នាំទី៨នេះ)។

## ១០. សន្និដ្ឋាន និង អនុសាសន៍

### ១០.១ សន្និដ្ឋាន

ការវិនិយោគលើគម្រោងនេះមានចំនួន ២៣២,២១ លានដុល្លារអាមេរិក (ទិន្នន័យបាន ពីក្រុមហ៊ុន KTC ក្នុងរបាយការណ៍ ការធ្វើបច្ចុប្បន្នភាពសមិទ្ធិលិទ្ធភាពគម្រោង ខែវិច្ឆិកា ឆ្នាំ២០១៧)។ ក្នុងទុនវិនិយោគនេះក្រុមហ៊ុនបានគិតគូរអំពីថវិកាសម្រាប់អនុវត្តន៍វិធានការ ការពារបរិស្ថានចំនួន ៨,៦៨៩លាន ដុល្លារអាមេរិកផងដែរ។

វារីអគ្គិសនីនេះមានកម្លាំងសរុប ៨០ MW ។

ថាពលអគ្គិសនីផលិតបានជាមធ្យមគឺ ៣៦៧,១២ GWh ក្នុងមួយឆ្នាំ។

គម្រោងនេះត្រូវការផ្ទៃដីចំនួនសរុប ៩.៣៥៥ហ.ត សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធវារីអគ្គិសនី ទំនប់ អាគារថាមពល ផ្លូវថ្នល់ ប្រព័ន្ធខ្សែបញ្ជូនអគ្គិសនី ២៣០គ.វ៉ ភ្ជាប់ទៅបណ្តាញខ្សែ ២៣០គ.វ៉ អូរសោម-ពោធិ៍សាត់។

ការសាងសង់របស់គម្រោងនេះនឹងធ្វើឱ្យប៉ះពាល់ផ្ទៃដីព្រៃឈើ សរុប៦,០០៧,២៤ហ.តក្នុងនោះការប៉ះពាល់ដោយសារការសាងសង់អាង(តំបន់១)៥.៨៣៥,៦ហ.ត(ព្រៃសោង៧៣៥ហ.ត ព្រៃពាក់កណ្តាលស្រោង ៨៤៧,៦ហ.ត និងព្រៃល្បោះ ៤.២៥៣ហ.ត), តំបន់២ប៉ះពាល់ព្រៃឈើ១២០.២៥ហ.ត (ព្រៃសោង ១១៩,១៨ហ.ត ព្រៃពាក់ កណ្តាលស្រោង ១,០៧ ហ.ត និងព្រៃល្បោះ ០ ហ.ត), តំបន់៣ជាតំបន់ខ្សែបញ្ជូន អគ្គិសនី២៣០គ.វ៉ ប៉ះពាល់ព្រៃឈើ ១២,៨៩ ហ.ត (ព្រៃសោង ១១,៣១ ហ.ត ព្រៃពាក់កណ្តាលស្រោង ១,៥៨ ហ.ត និងព្រៃល្បោះ០ ហ.ត) និងតំបន់៤ គឺតំបន់សម្រាប់ តាំងទីលំនៅថ្មីប៉ះពាល់ព្រៃឈើ ៣៨,៥ហ.ត(ព្រៃសោង០ហ.ត ព្រៃពាក់កណ្តាលស្រោង០ហ.ត និងព្រៃល្បោះ ៣៨,៥ ហ.ត)។

គម្រោងនេះនឹងអាចធ្វើឱ្យបាត់បង់ទាំងស្រុងនូវព្រៃស្រោង ដែលមានផ្ទៃដីសរុប ៨៦៥,៤៦ ហ.ត ព្រៃពាក់កណ្តាលស្រោង សរុប៨៥០,២៥ ហ.ត ព្រៃល្បោះសរុប ៤.២៩១,៥ហ.ត មានដង់ស៊ីតេមាឌជាមធ្យម ៥១,៥៦ ម៣/ហ.ត (គិតអង្កត់ផ្ចិត ឈើពី១០ស.មឡើងទៅ) និងឈើដែលមានអង្កត់ ផ្ចិត៣០ស.ម គឺ៣៤,៦០ ម៣/ហ.ត។ ការបាត់បង់ ព្រៃឈើ

ទាំងស្រុង ក្នុងតំបន់អាង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី នឹងធ្វើការដេញថ្លៃបង់ចូលជា ថវិកាជាតិដោយតម្លាភាព។ *សម្គាល់: តម្លៃនៃការបាត់ព្រៃឈើនេះ មាន ១.០៤៩.៥៥១ ដុល្លារ /ឆ្នាំ*

នៅក្នុងតំបន់គម្រោងក្រុមការងារបានរកឃើញពពួកសត្វព្រៃ រួមមាន: ថនិកសត្វចំនួន៤៥ ប្រភេទ បក្សី១០១ ប្រភេទ ឧរង្គសត្វ និងថលជលិកសត្វ ៥៤ប្រភេទ និងត្រីទឹកសាប ៧៨ប្រភេទ។

តាមការសិក្សាកម្រិតធារទឹកនៅទីតាំងទំនប់មេរបស់ក្រុមហ៊ុន HEC បានឱ្យដឹងថាកម្រិតធារទឹកមធ្យមក្នុង១ឆ្នាំ សម្រាប់ខួប៣០ឆ្នាំ នៅទំនប់មេ នារដូវវស្សាចន្លោះពីខែឧសភា-តុលា (រដូវវស្សា) មាន២១,៥ម$^{៣}$/វិនាទី។ កម្រិតធារទឹកធំជាងគេជាមធ្យមប្រចាំខែ គឺនៅខែតុលា ឆ្នាំ២០១០ គឺ៣៨៩,២ម$^{៣}$/វិនាទី។ កម្រិតធារទឹកអប្បបរមាជាមធ្យមប្រចាំខែ នៅខែកុម្ភៈ ឆ្នាំ២០០៦ និងមិនា ឆ្នាំ១៩៨១ គឺ០,៦ម$^{៣}$/វិនាទី។ ចំពោះកម្រិតធារទឹកមធ្យមសម្រាប់ខួប៣០ឆ្នាំ នៅរដូវប្រាំង ពីខែវិច្ឆិកា ដល់ខែមេសា វិញ មាន ៦២,៨ ម$^{៣}$/វិនាទី។

គម្រោងនេះ នឹងមានការខ្វះខាតទឹករក្សាជីវៈចម្រុះរបស់កំណាត់ស្ទឹងពោធិ៍សាត់នៅចន្លោះទំនប់ និងអាគារថាមពល ចម្ងាយប្រមាណ៩,២គ.ម។ ទោះបីជាយ៉ាងនេះក៏ដោយ ក្រុមហ៊ុនមានគ្រោងធ្វើកន្លែងបង្ហូរទឹកមកខាងក្រោមតំបន់នេះចំនួន ១.៣ ម$^{៣}$/វិនាទី ទាំងប្រាំង និងវស្សាក្នុងពេលប្រតិបត្តិ និងថែទាំគម្រោង។

## ១០.២ អនុសាសន៍

ក្នុងពេលសាងសង់គម្រោងម្ចាស់គម្រោងត្រូវមានកន្លែងទុកដាក់សំណល់ផ្ទះបាយ (កំប៉ុង ដប ស្បោងប្លាស្ទិក ប្រអប់ស្នោរ សម្រាប់ដាក់បាយ និងសំណល់កំទេចអាហារ) ឱ្យបានល្អ ដោយមានរណ្ដៅត្រឹមត្រូវ ដែលមានការថែទាំជាប្រចាំ។ ជាងនេះទៅទៀតម្ចាស់គម្រោង និងអ្នកម៉ៅការបន្ត ត្រូវធ្វើបង្គន់អនាម័យឱ្យបានគ្រប់គ្រាន់ទៅតាមចំនួនកម្មករបុគ្គលិកគម្រោង។

ក្រុមហ៊ុនត្រូវសហការណ៍ជាមួយក្រសួងរ៉ែ និងថាមពល ត្រួតពិនិត្យមើលបូឡុង និងខ្សៅនៅតាមបង្គោលភ្លើង២៣០គ.វ៉ ដោយជឿជាក់ថាប៊ូឡុង ខ្សៅ ទាំងអស់បានរឹតតឹងត្រឹមត្រូវតាមបច្ចេកទេស និងមិនមានការបាត់បង់សូម្បីតែ ១គ្រាប់ឡើយ។

ក្រុមហ៊ុនត្រូវធ្វើសហប្រតិបត្តិការណ៍ពេញលេញ (ទាំងថវិកា និងបច្ចេកទេស) ជាមួយរដ្ឋបាលព្រៃឈើ, ក្រសួងបរិស្ថាន, ក្រសួងរ៉ែ និងថាមពល, និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការអភិរក្សនានា ដើម្បីដាំព្រៃឈើឡើងវិញក្នុងតំបន់ក្បែរខាង និងទប់ស្កាត់ការទន្ទ្រានកាន់កាប់ ដីព្រៃឈើធ្វើជាកម្មសិទ្ធិខុសច្បាប់ នេះបានន័យថាគម្រោងបានរួម ចំណែកស្ដារឡើងវិញនូវការបាត់បង់ព្រៃឈើ និងជាជម្រកសត្វព្រៃ ហើយធ្វើឱ្យមានលំនឹងបរិស្ថាន នៃការអភិរក្សព្រៃការពារ និង តំបន់ការពារទាំងនោះទៀតផង។ ជាពិសេសត្រូវលើស្លាកប៉ាន់ណូធំៗ នៅក្នុងតំបន់គម្រោងយ៉ាងហោចណាស់ឱ្យបាន៤ ដូចជា សរសេរថា « ព្រៃ(តំបន់) ការពារហាមទន្ទ្រានកាន់កាប់ ធ្វើជាកម្មសិទ្ធ ហាមកាប់ឈើ ឬបរបាញ់ខុសច្បាប់ ជនល្មើសត្រូវដាក់គុក រហូតដល់១០ឆ្នាំ » ហើយនៅតាមគន្លងខ្សែ២៣០គ.វ៉ ត្រូវដាក់ស្លាកតាមបង្គោលអគ្គិសនីនូវសេចក្ដីជូនដំណឹងអំពីចំណីគន្លងខ្សែនៅរៀងរាល់ ២បង្គោលម្ដង ឱ្យបានច្បាស់ងាយមើលឃើញពីចម្ងាយ។

ដើម្បីចីរភាពនៃដំណើរការប្រតិបត្តិវារីអគ្គិសនីនេះ គឺត្រូវរក្សាកម្រិតកម្ពស់ទឹកនៅក្នុងអាង ដោយត្រូវការពារ និងថែរក្សាគម្របព្រៃឈើនៅជុំវិញតំបន់គម្រោងឱ្យបានល្អ ជាពិសេសព្រៃឈើខ្ពស់ៗសម្រាប់ស្រូបទាញទឹកភ្លៀង។

ក្រុមហ៊ុនត្រូវមានការប្រុងប្រយ័ត្ន និងត្រៀមគ្រប់គ្រងហានិភ័យឱ្យបានកម្រិតខ្ពស់ ដូចជាការសិក្សាភូគព្ភសាស្ត្រ និងបរិស្ថានក្នុងតំបន់គម្រោងឱ្យបានហ្មត់ចត់ ការរចនាប្លង់ គុណភាពសំណង់ធានាបានមិនឱ្យមានការបាក់ទំនប់ បាក់ភ្នំ ឬរញ្ជួយដី។ ត្រៀមគ្រប់គ្រងហេតុការណ៍ដែលអាចកើតឡើងចៃដន្យ ដោយប្រព័ន្ធផ្សព្វផ្សាយគ្រប់គ្រាន់ និងទាន់ពេលវេលា អ្នកជួយសង្គ្រោះ និងសម្ភារសង្គ្រោះព្រមទាំងថវិកាសម្រាប់ដោះស្រាយជាបន្ទាន់ទៀតផង។ ជាងនេះទៅទៀត ម្ចាស់គម្រោងត្រូវរកក្រុមហ៊ុនធានារ៉ាប់រងបរទេស ដើម្បីធ្វើការធានាលើជនទី៣ ចំពោះហានិភ័យ ដែលអាចកើតមានឡើង ដូចជាការបាក់ទំនប់ ការបាក់ររិលភ្នំ ជាដើម។ល។

Draft